**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** **ក្រសួងសុខាភិបាល**

**លេខ**............១៧៣......**ក.ប**/ប្រ.ក

# ប្រកាសអន្តរក្រសួង
# ស្តីពី
# យន្តការទូទាត់ថ្លៃសេវាថែទាំសុខភាព

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** **រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ ជស/រកម ០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម

# សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់យន្តការទូទាត់ថ្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះ សេវាបញ្ជូនសព សម្រាប់ផ្នែកថែទាំសុខភាព ដែល ប.ស.ស ត្រូវផ្តល់ជូនមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀង ឬ មូលដ្ឋានសុខាភិបាលដែលបានផ្តល់សេវាសង្គ្រោះបន្ទាន់។

**ប្រការ ២.-**

វាក្យស័ព្ទសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះមានដូចតទៅ ៖

- ***យន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព*** សំដៅដល់វិធីសាស្ត្រនៃការទូទាត់ថ្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនអ្នកជំងឺ ឬ ជនរងគ្រោះ និងសេវាបញ្ជូនសព សម្រាប់ផ្នែកថែទាំសុខភាព ។
- ***សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ*** សំដៅដល់សេវាវេជ្ជសាស្ត្រ សេវាអមវេជ្ជសាស្ត្រ និងសេវាជំនួយវេជ្ជសាស្ត្រ។
- ***សេវាវេជ្ជសាស្ត្រ*** សំដៅដល់សេវាពិគ្រោះជំងឺក្រៅ និងសេវាសម្រាកពេទ្យ។
- ***សេវាអមវេជ្ជសាស្ត្រ*** សំដៅដល់សេវាមន្ទីរពិសោធន៍ និងរូបភាពវេជ្ជសាស្ត្រ។
- ***សេវាជំនួយវេជ្ជសាស្ត្រ*** សំដៅដល់ការព្យាបាលដោយស្នំ និងដោយចលនា។
- ***សេវាស្តារនីតិសម្បទា*** គឺជាសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រសម្រាប់ផ្នែកថែទាំសុខភាពក្នុងគោលបំណងជួយដល់ជនរងគ្រោះរក្សា ស្តារ ឬ ធ្វើឲ្យប្រសើរឡើងវិញនូវសមត្ថភាព ជំនាញ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ និងជំនាញប្រាស្រ័យទាក់ទងដែលបានបាត់បង់ ឬ ខូចខាតដោយសារជំងឺ ការរងរបួស ឬពិការភាព។

- ***វិធីសាស្ត្រទូទាត់តាមករណី*** សំដៅដល់ការទូទាត់ក្នុងអត្រាថេរមួយ ដែលគ្របដណ្តប់លើគ្រប់តម្លៃសេវាសម្រាប់មួយករណីនៃអ្នកជំងឺម្នាក់ ឬប្រភេទជំងឺជាក់លាក់ណាមួយ។
- ***វិធីសាស្ត្រទូទាត់តាមប្រភេទសេវា*** គឺជាការទូទាត់ថ្លៃសេវាដោយផ្អែកទៅលើប្រភេទសេវាផ្សេងៗគ្នា ហើយមានតម្លៃដាច់ដោយឡែកពីគ្នា។
- ***អន្តរាគមន៍*** សំដៅដល់សកម្មភាពព្យាបាល ឬជួយសង្គ្រោះជនរងគ្រោះ ឬអ្នកជំងឺដែលស្ថិតនៅក្នុងស្ថានភាពរឹករវ។
- ***មូលដ្ឋានសុខាភិបាល*** សំដៅដល់អង្គភាពព្យាបាលសាធារណៈ ឬឯកជនដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល។

**ប្រការ ៣.-**

យន្តការនៃការទូទាត់ថ្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវបានកំណត់តាមវិធីសាស្ត្រពីរយ៉ាង គឺវិធីសាស្ត្រទូទាត់ថ្លៃតាមករណី និង វិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទសេវា។

វិធីសាស្ត្រទូទាត់ថ្លៃតាមករណី ត្រូវបានប្រើប្រាស់សម្រាប់ទូទាត់តាមអត្រាតម្លៃថេរតាមប្រភេទករណីជំងឺ និងតាមកម្រិតមូលដ្ឋានសុខាភិបាលនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

វិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទសេវា ត្រូវបានអនុវត្តចំពោះប្រភេទសេវាសម្រាប់ករណីពិសេស ដូចមានចែងក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

វិធីសាស្ត្រដែលកំណត់នៅក្នុងប្រកាសនេះ ត្រូវអនុវត្តសម្រាប់ផ្នែកថែទាំសុខភាព ដែលស្ថិតនៅក្នុងដែនអនុវត្តរបស់ ប.ស.ស និងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយគ្នា។

**ប្រការ ៤.-**

ប.ស.ស ត្រូវទូទាត់សងទៅមូលដ្ឋានសុខាភិបាល ឬសាមីជន តាមវិធីសាស្ត្រទូទាត់ថ្លៃដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ ក្នុងករណីសង្គ្រោះបន្ទាន់។ ក្នុងករណីនេះ ជនរងគ្រោះ ឬ អ្នកជំងឺអាចទៅព្យាបាលនៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុត ។

ប្រសិនបើ ការសង្គ្រោះបន្ទាន់ធ្វើនៅក្នុងមូលដ្ឋានសុខាភិបាល ដែលមិនមានកិច្ចព្រមព្រៀងជាមួយ ប.ស.ស សាមីជន ឬ អ្នកតំណាងត្រូវជូនដំណឹងជាបន្ទាន់មក ប.ស.ស។

**ប្រការ ៥.-**

ការទូទាត់ថ្លៃសេវាបញ្ជូនជនរងគ្រោះ ឬ អ្នកជំងឺ សម្រាប់ផ្នែកថែទាំសុខភាព ត្រូវផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ ដែលប្រើប្រាស់ប្រភេទមធ្យោបាយបញ្ជូនដោយរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាល ឬមធ្យោបាយផ្សេងទៀតដែលមានលិខិតបញ្ជាក់ច្បាស់លាស់។

ការទូទាត់ថ្លៃសេវាបញ្ជូន ត្រូវអនុវត្តគោលការណ៍ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ ៦.-**

ការបញ្ជូនសព ឬ បញ្ជូនអ្នកជំងឺធ្ងន់ធ្ងរព្យាបាលមិនជា អាចធ្វើតាមមធ្យោបាយបញ្ជូនរបស់មូលដ្ឋានសុខាភិបាល ឬ ប្រភេទមធ្យោបាយជាក់ស្តែងផ្សេងទៀត។ ការទូទាត់ថ្លៃសេវាបញ្ជូននេះ ត្រូវអនុវត្តគោលការណ៍ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ ៧.-**

ការទូទាត់ថ្លៃសេវាស្តារនីតិសម្បទា ត្រូវអនុវត្តគោលការណ៍ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី ២ នៃប្រកាសនេះ។

**ប្រការ ៨.-**

របៀបទូទាត់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ចំពោះមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ត្រូវកំណត់នៅក្នុងប្រកាសអន្តរក្រសួងស្តីពីកិច្ចព្រមព្រៀងប្រើប្រាស់និងផ្តល់សេវារវាងបេឡាជាតិរបបសន្តិសុខសង្គមជាមួយមូលដ្ឋានសុខាភិបាល ដែលចេញដោយរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**ប្រការ ៩.-**

រៀងរាល់ដំណាច់ឆ្នាំ ប.ស.ស ត្រូវវិភាគវាយតម្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ដោយផ្អែកលើតម្លៃសេវាហិរញ្ញប្បទាន និងតម្លៃចំណាយផ្សេងៗ ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល។

ការកែប្រែប្រភេទករណី ឬតម្លៃទូទាត់សេវាដូចមានចែងក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ ត្រូវធ្វើឡើងដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមសំណើក្រុមប្រឹក្សាភិបាលនៃប.ស.ស បន្ទាប់ពីបានទទួលយោបល់ពីគណៈកម្មការវេជ្ជសាស្ត្រនៃប.ស.ស។

និយមន័យនៃករណីក្នុងយន្តការទូទាត់ថ្លៃសេវាដូចមាន ចែងក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ អាចត្រូវបានកំណត់ឡើងវិញ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃប.ស.ស បន្ទាប់ពីបានទទួលយោបល់ពីគណៈកម្មការវេជ្ជសាស្ត្រនៃប.ស.ស។

**ប្រការ ១០.-**

វិធីសាស្ត្រទូទាត់ដទៃទៀត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃប.ស.ស បន្ទាប់ពីទទួលយោបល់ពីគណៈកម្មការវេជ្ជសាស្ត្រនៃប.ស.ស ដោយយោង

តាមស្ថានភាពជាក់ស្តែង នៃការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងការវិភាគហិរញ្ញវត្ថុនៃផ្នែកថែទាំសុខភាព។

**ប្រការ ១១.-**

នាយកបេឡាជាតិរបបសន្តិសុខសង្គម មូលដ្ឋានសុខាភិបាល អង្គភាពក្រោមឱវាទក្រសួងសុខាភិបាល និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្ថាប័នពាក់ព័ន្ធ និយោជកម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

*ឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រ.ក. ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព*

## វិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទករណី

ឧបសម្ព័ន្ធនេះមានគោលបំណងរៀបចំវិធីសាស្ត្រទូទាត់ថ្លៃតាមករណី សំរាប់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ផ្នែកថែទាំសុខភាព។ ទិដ្ឋភាពរួមនៃវិធីសាស្ត្រទូទាត់តាមករណីត្រូវបានចែងនៅក្នុងតារាងភ្ជាប់មកជាមួយ។

**១-ចំនួន និងកំរិតប្រភេទករណី៖** (ជួរឈរលេខ១ក្នុងតារាង) វីធីសាស្ត្រទូទាត់តាមករណីបានកំណត់យកប្រភេទករណី សរុបចំនួន ៤៩ ដែលត្រូវបានបែងចែកចេញជា ៥ កំរិតនៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រគឺ: កំរិត MPA សំរាប់មណ្ឌលសុខភាព កំរិត CPA1 សំរាប់មន្ទីរពេទ្យបង្អែកកំរិត១ កំរិត CPA2 សំរាប់មន្ទីរពេទ្យបង្អែកកំរិត២ កំរិត CPA3 សំរាប់មន្ទីរពេទ្យបង្អែកកំរិត៣ និង កំរិត NH សំរាប់មន្ទីរពេទ្យជាតិ ដូចមានចែងនៅក្នុងគោលការណ៍ណែនាំស្តីពីសំណុំសកម្មភាពអប្បបរមា និងសំណុំសកម្មភាពបង្គ្រប់របស់ក្រសួងសុខាភិបាល។

**២-លេខកូដ៖** (ជួរឈរលេខ២ក្នុងតារាង) រាល់ប្រភេទករណីនីមួយៗមានលេខកូដមួយ ដែលផ្គុំឡើងដោយតួអក្សរឡាតាំង៣តួនៅខាងមុខ និងលេខមួយតួនៅខាងចុង។ អក្សរឡាតាំងទាំង៣តួ ភាគច្រើនបំផុត យកចេញពីតួអក្សរឡាតាំង៣តួ ដំបូងនៃឈ្មោះករណីដែលអាចចាត់ទុកថាជាឈ្មោះសង្ខេប រីឯលេខមួយតួខាងចុងតំណាងកំរិតសេវា ពោលគឺ: លេខ0 តំណាងកំរិតMPA, លេខ1 តំណាងកំរិតCPA1, លេខ2 តំណាងកំរិត CPA2, លេខ3 តំណាងកំរិត CPA3, និង លេខ4 តំណាងកំរិត NH។ លេខកូដនឹងត្រូវប្រើជាពិសេសសំរាប់បច្ចេកវិទ្យាប្រព័ន្ធទំនាក់ទំនងព័ត៌មានសំរាប់សំរួលដល់ការត្រួតពិនិត្យតាមដានវាយតំលៃ ធ្វើរបាយការណ៍ និងដំណើរការទូទាត់ផ្សេងៗ។

**៣-ឈ្មោះករណី៖** (ជួរឈរលេខ៣ក្នុងតារាង) ឈ្មោះករណីនឹងត្រូវប្រើរួមគ្នាជាមួយលេខកូដសំរាប់គោលបំណងត្រួតពិនិត្យតាមដានវាយតំលៃ ធ្វើរបាយការណ៍ និងដំណើរការទូទាត់ផ្សេងៗដោយឡែក។

**៤-ការបរិយាយ/និយមន័យករណី៖** (ជួរឈរលេខ៤ក្នុងតារាង) ការបរិយាយ/និយមន័យ ករណីដែលមានលក្ខណៈស្របទៅនឹងការអនុវត្តន៍ជាក់ស្តែងអនុញ្ញាតឲ្យមូលដ្ឋានសុខា

ភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស កំណត់ និងបែងចែកករណីអ្នកជំងឺ ឬអ្នកប្រើប្រាស់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រទៅតាមប្រភេទករណីនីមួយៗ។

**៥-បញ្ជីរាយនាមស្ថានភាពវេជ្ជសាស្ត្រ/រោគវិនិច្ឆ័យដែលពាក់ព័ន្ធ៖** (ជួរឈរលេខ៥ក្នុងតារាង) បញ្ជីរាយនាមស្ថានភាពវេជ្ជសាស្ត្រ/រោគវិនិច្ឆ័យ ដែលពាក់ព័ន្ធនានាប្រើសំរាប់ជាជំនួយបន្ថែមដល់មូលដ្ឋានសុខាភិបាលក្នុងការកំណត់ និងបែងចែកប្រភេទករណីក៏ដូចជាការធ្វើលំហាត់ ដើម្បីឈានឆ្ពោះទៅការអនុវត្តន៍យន្តការទូទាត់តាមប្រភេទរោគវិនិច្ឆ័យ (Diagnostic related group) ទៅថ្ងៃមុខ។

ដោយសារបញ្ជីរាយនាមស្ថានភាពវេជ្ជសាស្ត្រ/រោគវិនិច្ឆ័យនេះ មិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយ មូលដ្ឋានសុខាភិបាលអាចប្រើតែការបរិយាយ/និយមន័យករណីសំរាប់កំណត់ប្រភេទករណីណាដែលស្ថានភាពវេជ្ជសាស្ត្រ/រោគវិនិច្ឆ័យ មិនមាននៅក្នុងបញ្ជីរាយនាមស្ថានភាពវេជ្ជសាស្ត្រ/រោគវិនិច្ឆ័យ។ សំរាប់ករណីសម្រាកពេទ្យ ការកំណត់ករណីនីមួយៗ នឹងត្រូវធ្វើឡើងនៅពេលអ្នកជំងឺចេញពីមន្ទីរពេទ្យ (ចេញដោយមានការអនុញ្ញាត ចេញដោយបញ្ជូន ឬ ចេញដោយស្លាប់)។សំរាប់ករណីដែលក្នុងរយៈពេលសម្រាកពេទ្យបានទទួលសេវាព្យាបាលថែទាំច្រើនផ្នែក នឹងត្រូវកំណត់ជាប្រភេទករណីមួយដែលមានតំលៃទូទាត់ខ្ពស់ជាងគេ។

ឧ. ករណីអ្នកជំងឺម្នាក់សម្រាកនៅផ្នែកសង្គ្រោះបន្ទាន់ រួចបន្តមកផ្នែកសល្យសាស្ត្រ និងចុងក្រោយត្រូវការវះកាត់ត្រូវចាត់ជាករណីវះកាត់ធំ និងទូទាត់តែសំរាប់ករណីវះកាត់ធំនេះទេ។

**៦-តំលៃទូទាត់៖** (ជួរឈរលេខ៦ក្នុងតារាង) តំលៃគិតជាប្រាក់រៀលដែល ប.ស.ស ត្រូវទូទាត់ឲ្យមូលដ្ឋានសុខាភិបាលសំរាប់ករណីនីមួយៗដែលបានកំណត់។ [1] តំលៃទូទាត់នេះគឺសម្រាប់គ្រប់សេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រទាំងអស់ដែលមូលដ្ឋានសុខាភិបាលចាំបាច់ ត្រូវផ្តល់ជូនសំរាប់ព្យាបាលថែទាំករណីជំងឺនោះតាមគោលការណ៍វិជ្ជាជីវៈ និងដែលមានចែងក្នុងតារាកាលិកដែលកំណត់ដោយប្រកាសស្តីពីតារាកាលិកថែទាំសុខភាព និងកិច្ចព្រមព្រៀងរវាងប.ស.ស និងមូលដ្ឋានសុខាភិបាល។ ប៉ុន្តែតំលៃទូទាត់នេះមិនរាប់បញ្ចូលថ្លៃសេវាបញ្ជូន និងថ្លៃសេវាអមវេជ្ជសាស្ត្រនានា ដែលមានចែងក្នុងឧបសម្ព័ន្ធទី២នៃប្រកាសនេះទេ។ ចំពោះមូលដ្ឋានសុខាភិបាលឯកជន ប.ស.ស អាចទូទាត់ រហូតដល់

---

[1] *សូមបញ្ជាក់ថា តំលៃត្រូវទូទាត់នេះត្រូវបានគណនាផ្អែកលើតំលៃចំណាយដោយមិនគិតប្រាក់ឧបត្ថម្ភធនពីរាជរដ្ឋាភិបាលរបស់មណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋមួយចំនួនដែលបានមកពីការសិក្សាតំលៃមណ្ឌលសុខភាព និងមន្ទីរពេទ្យដែលបានធ្វើឡើងដោយក្រសួងសុខាភិបាលកន្លងមក ព្រមទាំងការលៃតំរូវទៅតាមកំរិត ដោយផ្ទៀងផ្ទាត់ជាមួយនឹងតំលៃហិរញ្ញប្បទាន និងតំលៃទូទាត់របស់មូលនិធិសមធម៌ ។*

១៥០% នៃតំលៃមូលដ្ឋានសុខាភិបាលសាធារណៈ ដោយផ្អែកតាមកំរិតសេវារបស់មូលដ្ឋានសុខាភិបាលឯកជននោះ ក្នុងករណីដែល ប.ស.ស មានការចាំបាច់ត្រូវចុះកិច្ចព្រមព្រៀងជាមួយ នៅទីតាំងដែលមិនមានសេវាសុខាភិបាលសាធារណៈសមស្រប។

ក្នុងការអនុវត្តន៍ជាក់ស្តែង ដើម្បីជំរុញការលើកកំពស់គុណភាពសេវា ប.ស.ស មានសិទ្ធិ ទូទាត់តិច ឬច្រើនជាងតំលៃត្រូវទូទាត់ដែលបានកំណត់ក្នុងតារាងនេះ (ចន្លោះពី ៨០% ទៅ ១២០%) ទៅតាមកំរិតគុណភាពសេវាដែលនឹងត្រូវវាស់វែង ឬ វាយតំលៃដោយយន្តការសមស្របមួយ។

**៧-ចំណាត់ថ្នាក់មូលដ្ឋានសុខាភិបាល៖** ដើម្បីអនុវត្តវិធីសាស្រ្តទូទាត់តាមករណីនេះ ប.ស.ស ត្រូវធ្វើការវាយតំលៃ និងចាត់ថ្នាក់មូលដ្ឋានសុខាភិបាល ដែលត្រូវចុះកិច្ចព្រមព្រៀងជាកំរិត MPA កំរិត CPA1 កំរិត CPA2 កំរិត CPA3 កំរិតចំរុះ ឬកំរិត NH ទៅតាមវិសាលភាព និងគុណភាពសេវារបស់មូលដ្ឋានសុខាភិបាលនោះ។ សូមបញ្ជាក់ថាមូលដ្ឋានសុខាភិបាលមួយ អាចទទួលកិច្ចព្រមព្រៀងសំរាប់សេវាច្រើនកំរិត (កំរិតចំរុះ)។ ឧ. សំរាប់មណ្ឌលសុខភាព មានគ្រែមួយ សេវាសម្រាកពេទ្យអាចចាត់ថ្នាក់ជាកំរិត CPA1 និងសេវាដទៃទៀតចាត់ថ្នាក់ជាកំរិត MPA។ មន្ទីរពេទ្យកំរិត CPA1 ខ្លះអាចមានសេវាវះកាត់ធំ។ ក្នុងករណីនេះសេវាវះកាត់ធំនេះអាចចាត់ថ្នាក់ជាកំរិត CPA2 បើទោះបីជាសេវាដទៃទៀតត្រូវបានចាត់ថ្នាក់ជាកំរិត CPA1 ក៏ដោយ។

សម្រាប់មណ្ឌលសុខភាពដែលមានទីតាំងនៅក្នុង ឬចំណុះការគ្រប់គ្រងរបស់មន្ទីរពេទ្យត្រូវចាត់ថ្នាក់ជាកំរិត MPA បើកំរិតសេវារបស់មណ្ឌលសុខភាពនោះគ្មានអ្វីខុសគ្នាពីមណ្ឌលសុខភាពដទៃទេនោះ។

| ល.រ | កូដ | ឈ្មោះករណី | ការបរិយាយ/និយមន័យករណី | ស្ថានភាពវេជ្ជសាស្ត្រ/រោគវិនិច្ឆ័យដែលពាក់ព័ន្ធ | តំលៃទូទាត់គិតជារៀល |
|---|---|---|---|---|---|
| 1 | CON0 | ករណីពិគ្រោះជំងឺក្រៅកំរិត MPA | ជាការពិគ្រោះជំងឺក្រៅករណីថ្មី និងករណីបន្តបន្ទាប់ នៅមណ្ឌលសុខភាព។ សេវាពិគ្រោះជំងឺក្រៅរួមមានៈ<br>- ការសាកសួរ<br>- ការពិនិត្យ<br>- ការអប់រំសុខភាព<br>- ការប្រឹក្សាយោបល់<br>- ការផ្តល់សៀវភៅសុខភាព<br>- ការផ្តល់សេវាអមវេជ្ជសាស្ត្រ (ធ្វើតេស្តឈាមរកមេរោគគ្រុនចាញ់ និងធ្វើភ្នាសកំហាករកមេរោគរបេង)<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យ ចេញអោយប្រើ)<br>- ការពិនិត្យ និងព្យាបាលបន្តជំងឺរបេងដូតឬហាង់សិន ត្រូវបានបញ្ចូលទៅក្នុងប្រភេទករណីនេះ។ | - ជំងឺផ្តាសសាយទូទៅ (Common Cold)<br>- ជំងឺផ្លូវដង្ហើមស្រួចស្រាវដែលមិនមានផលវិបាក (Uncomplicated Acute Respiratory Infection)<br>- ជំងឺរាគមិនបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (Diarrhea Without Server Dehydration)<br>- ជំងឺគ្រុនចាញ់គ្មានផលវិបាក (Uncomplicated Malaria)<br>- ជំងឺរបេង/ឃ្លង់ ឬសង្ស័យរបេង/ឃ្លង់គ្មានផលវិបាក (Tuberculosis/leprosy or Suspected and Uncomplicated Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀនគ្មានផលវិបាក (Uncomplicated Typhoid Fever)<br>- ជំងឺភ្នែកក្រហមស្រួចស្រាវ (Acute Conjunctivitis)<br>- ជំងឺរលាកត្រចៀកកណ្តាល ( Otitis Media )<br>- ជំងឺពុកធ្មេញ ( Dental Caries )<br>- ជំងឺដង្កូវពោះវៀន (Intestinal Parasites)<br>- ចង្កោមរោគសញ្ញាជំងឺកាមរោគ | ៤.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | (Sexual Transmitted Infection Syndrome)<br>- ជំងឺសើស្បែក (Skin disease)<br>- ឈឺក្បាល អស់កំលាំង ក្តៅខ្លួនមិនដឹងមូលហេតុ(Headache, Fatigue, Fever… of unknown origin)<br>- ជំងឺលើសឈាមគ្មានផលវិបាក (Uncomplicated Hypertension) ។ | |
| 2 . | REFO | ករណីសង្គ្រោះបន្ទាន់ និងបញ្ជូនកំរិត MPA | ជាសេវាសង្គ្រោះបឋម និងការបញ្ជូនចេញពីមណ្ឌលសុខភាព ដោយគិតរួមបញ្ចូលទាំង៖<br>- លិខិតបញ្ជូន<br>- ការបញ្ចូលសេរ៉ូម<br>- សេវាសង្គ្រោះបឋមក្នុងពេលបញ្ជូន<br>- ការពិនិត្យតាមដានចាំបាច់ដទៃទៀតតែមិនគិតរួមបញ្ចូលថ្លៃដឹកជញ្ជូនតាមរថយន្តគិលានសង្គ្រោះ ឬតាមមធ្យោបាយផ្សេងៗទេ។ | - ជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរដូចជា៖ ជំងឺរលាកសួត ឬជំងឺហឺត ( Pneumonia/Asthma)<br>- ជំងឺរាគរ៉ាំរ៉ៃ ឬជំងឺរាគមានការបាត់បង់ជាតិទឹកធ្ងន់ធ្ងរ(Chronic Diarrhea or Diarrhea with Severe Dehydration)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរ(Complicated Malaria)<br>- សង្ស័យជំងឺរបេងសួត ឬ របេងក្រៅសួតធ្ងន់ធ្ងរ (Suspected Severe Pulmonary/ Extra-pulmonary Tuberculosis )<br>- ជំងឺគ្រុនពោះវៀនមានផលវិបាក (Complicated Typhoid Fever)<br>- សង្ស័យជំងឺគ្រុនឈាម (Suspected Dengue Fever) | ១០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺលើសឈាមមានផលវិបាក ឬ គ្រោះថ្នាក់ដាច់ ឬ ស្ទះសរសៃឈាមខួរក្បាល (Hypertension with Complication/Stroke)<br>- ការសម្រាលកូនពិបាក (Complicated Delivery)<br>- លង់ទឹក (Drown)<br>- ស្ហុក (Shock)<br>- ការប្រកាច់ (Convulsion)<br>- សន្លប់ (Coma)<br>- បាក់ឆ្អឹង (Bone Fracture)<br>- រលាក ឬ ហូរឈាមធ្ងន់ធ្ងរ (Severe Burn or Hemorrhage)<br>- ពស់ចឹក (Snake Bite)<br>- ឆ្កែខាំ (Dog Bite)<br>- សត្វទិច/ខាំ ដែលអាចបង្កអោយមានគ្រោះថ្នាក់<br>- ស្ថានភាពវេជ្ជសាស្ត្រស្មុគស្មាញផ្សេងទៀត ដែលមណ្ឌលសុខភាព មិនមានលទ្ធភាពពិនិត្យព្យាបាល ។ | |
| 3 | MINO | ករណីវះកាត់តូចកំរិត MPA | ជាសកម្មភាពវះកាត់តូចមិនសម្រាកពេទ្យដែលរួមមាន៖ | - បូសធម្មតា ( Cutaneous Abscess )<br>- របួសតូច ( Small Wound ) | ១២.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | - ការចាក់ថ្នាំស្ពឹក ( Local Anesthesia )<br>- ការវះកាត់<br>- ការលាងសំអាត<br>- ការដេររបួស<br>- ការរុំរបួស<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញអោយប្រើ)<br>- សេវាចាំបាច់ដទៃទៀត សម្រាប់ករណីសល្យសាស្រ្តតូចនៅមណ្ឌលសុខភាព។ | - រលាកស្រាល ( Mild Burn ) ។ | |
| 4 | PREO | ករណីសេវាបង្ការ និងពន្យារកំណើត រយៈពេលខ្លី កំរិត MPA | - ជាការពន្យារកំណើតករណីថ្មី និងករណីបន្តបន្ទាប់ (រួមទាំងការប្រឹក្សា និងវិធីសាស្រ្តពន្យារកំណើតទំនើប ដូចជា ស្រោមអនាម័យ ថ្នាំគ្រាប់ឬថ្នាំចាក់)<br>- ការពិនិត្យផ្ទៃពោះមុនសំរាល (រួមទាំងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត)<br>- ការពិគ្រោះក្រោយសំរាល<br>- ការព្យាបាលថែទាំក្រោយរលូត | - ការថែទាំមុនសំរាល (Antenatal Care)<br>- ការពន្យារកំណើត (Birth Spacing)<br>- ការថែទាំក្រោយសំរាល (Postnatal Care)<br>- ការព្យាបាលថែទាំក្រោយរលូត (Postabortion Care)<br>- ការចាក់ថ្នាំបង្ការ ( Vaccination )។ | ១០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | - ការចាក់ថ្នាំបង្ការនៅ មណ្ឌលសុខភាព។ | | |
| 5 | BSLO | សេវាពន្យារកំណើតរយៈពេលវែង កំរិត MPA | ជាការពន្យារកំណើតសម្រាប់ករណីថ្មី និងករណីបន្តបន្ទាប់ ដោយរួមបញ្ចូលៈ<br>- ការដាក់កងក្នុងស្បូន ឬ ដាក់កងក្នុងដៃស្បូន<br>- ការប្រឹក្សាពីវិធីសាស្រ្តពន្យារកំណើតនៅមណ្ឌលសុខភាព។ | - ការពន្យារកំណើតរយៈពេលវែង ( Prolonged Birth Spacing)។ | ២០.០០០ |
| 6 | DELO | ករណីសំរាលកូនកំរិត MPA | ជាការសំរាល និងសេវាចាំបាច់ដទៃទៀតរួមមានៈ<br>- ការបញ្ចូលសេរ៉ូម<br>- ការចាក់ថ្នាំ Oxytocin ជាចំណែកមួយនៃការគ្រប់គ្រង ការសំរាលសកម្មដំណាក់កាលទី៣ (AMTSL)<br>- ការដេរស្នាមកាត់ឬដាច់ទ្វារមាស<br>- ការថែទាំ និងសង្គ្រោះទារកនៅពេលកើតភ្លាម<br>- ការថែទាំនិងតាមដានក្រោយសំរាលសំរាប់ករណីសំរាលកូនធម្មតា នៅ | - ការសំរាលកូនធម្មតា (Normal delivery)។ | ៨០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | មណ្ឌលសុខភាព។ | | |
| 7 | CON1 | ករណីពិគ្រោះជំងឺក្រៅកំរិត CPA1 | ជាការពិគ្រោះជំងឺក្រៅករណីថ្មី និង ករណីបន្តបន្ទាប់រួមទាំងការពិគ្រោះបញ្ជូន (Referral consultations) នៅមន្ទីរពេទ្យបង្អែកកម្រិត១។សេវាពិគ្រោះរួមមាន៖<br>- ការសាកសួរ<br>- ការពិនិត្យ<br>- ការអប់រំសុខភាព<br>- ការប្រឹក្សាយោបល់<br>- ការផ្តល់សៀវភៅសុខភាព<br>- ការផ្តល់សេវាអមវេជ្ជសាស្ត្រ ( សេវាមន្ទីរពិសោធន៍មូលដ្ឋាន អេកូសាស្ត្រ ការថតកាំរស្មីអ៊ិច ការវាស់អគ្គិសនីបេះដូង)<br>- កាព្យាបាលនិងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញអោយប្រើ)<br>- សេវាបញ្ជូនបន្ទាន់សម្រាប់អ្នកជំងឺក្រៅ ត្រូវបានបញ្ចូលទៅក្នុងប្រភេទករណីនេះ (ដោយមិនគិតថ្លៃសេវា | - ជំងឺផ្តាសសាយទូទៅ (Common Cold)<br>- ជំងឺផ្លូវដង្ហើមស្រួចស្រាវ ដែលមិនមានផលវិបាក(Uncomplicated Acute Respiratory Infections)<br>- រាគមិនបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (Diarrhea without Severe Dehydration)<br>- ជំងឺគ្រុនចាញ់គ្មានផលវិបាក (Uncomplicated Malaria)<br>- ជំងឺរបេង/ឃ្លង់ ឬសង្ស័យរបេង/ឃ្លង់ គ្មានផលវិបាក(Tuberculosis/Leprosy or Suspected uncomplicated Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀនគ្មានផលវិបាក ( Uncomplicated Typhoid Fever )<br>- ជំងឺគ្រុនឈាមគ្មានផលវិបាក ( Uncomplicated Dengue Fever )<br>- ជំងឺភ្នែកក្រហមស្រួចស្រាវ (Acute Conjunctivitis)<br>- រលាកត្រចៀកកណ្តាល (Otitis Media)<br>- ជំងឺពុកធ្មេញ (Dental Caries) | ៨.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | ដឹកជញ្ជូនតាមរថយន្តគិលានសង្គ្រោះ ឬតាមមធ្យោបាយផ្សេងៗទេ)។ | - ជំងឺដង្កូវពោះវៀន (Intestinal Parasites)<br>- ចង្កោមរោគសញ្ញាជំងឺកាមរោគ(Sexually Transmitted Infection Syndrome)<br>- ជំងឺសើស្បែក (Skin Disease)<br>- ឈឺក្បាល អស់កំលាំង ក្តៅខ្លួនមិនដឹងមូលហេតុ ( Headache, Fatigue, Fever… of Unknown Origin)<br>- ស្ថានភាពដទៃទៀតដែលមិនអាចគ្រប់គ្រងបាននៅមណ្ឌលសុខភាព ប៉ុន្តែមិនត្រូវការសម្រាកពេទ្យ។<br>- ករណីបញ្ជូនបន្ទាន់រួមមាន៖<br>• រលាកស្រោមខួរក្បាល គិតរួមទាំងរលាកស្រោមខួរក្បាល ដោយមេរោគរបេង (Meningitis Including Tuberculosis Meningitis)<br>• រលាកខួរក្បាល ( Encephalitis )<br>• របេងសួតទំរង់ធ្ងន់ធ្ងរ (MiliaryTuberculosis)<br>• តេតាណូស (Tetanus )<br>• ស្ថានភាពវេជ្ជសាស្ត្រដូចមានថៃងក្នុង | |

| | | | | | |
|---|---|---|---|---|---|
| | | | | ប្រភេទករណី EMG1 ដែលត្រូវការបញ្ជូនបន្ទាន់។ | |
| 8 | MIN1 | ករណីវះកាត់តូចកំរិត CPA1 | ជាសកម្មភាពវះកាត់តូចមិនសម្រាកពេទ្យ ដែលរួមមាន៖<br>- ការចាក់ថ្នាំស្ពឹក ( Local Anesthesia)<br>- ការវះកាត់<br>- ការបង្ហូរខ្ទុះ(Drainage)<br>- ការលាងសំអាត<br>- ការដេររបួស<br>- ការរុំរបួស<br>- ការព្យាបាល និង ការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញអោយប្រើ)<br>- សេវាចាំបាច់ដទៃទៀតសម្រាប់ករណីសល្យសាស្ត្រតូចនៅមន្ទីរពេទ្យបង្អែកកម្រិត១។ | - បូសធម្មតា (Cutaneous Abscess)<br>- អាប់សែរាក់ៗ (Superficial Abscess)<br>- របួសតូច (Small Wound)<br>- រលាកកំរិតស្រាល (Mild Burn)<br>- រលាកសាច់ដុំកំរិតមធ្យម (Moderate Myositis)<br>- គីសស្បែក (Sebaceous Cyst)<br>- ដុំខ្លាញ់ (Lipoma)<br>- ការវះកាត់ស្បែកនៅចុងលឹង្គ (Phymosis or Paraphymosis Circumcision)<br>- ការដកធ្មេញ ( Tooth Extraction )។ | ១៦.០០០ |
| 9 | EMG1 | ករណីសង្គ្រោះបន្ទាន់កំរិត CPA1 | ជាអន្តរាគមន៍(វេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ) សង្គ្រោះជីវិត ឬ អវៈយវៈណាមួយនៃសរីរាង្គរបស់អ្នកជំងឺ ឬជនរងគ្រោះ ដែលចាំបាច់ផ្តល់ដោយផ្នែកសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យបង្អែកកម្រិត១ដោយសំរាក | ស្ថានភាពវេជ្ជសាស្ត្រណាក៏ដោយ ដែលត្រូវការសង្គ្រោះជីវិតបន្ទាន់រួមមាន៖<br>- លង់ទឹក (Drown)<br>- វិបត្តិដង្ហើម (Respiratory Distress )<br>- ស្ហុក ( Shock) | ១២០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | ពេទ្យ។ | - ប្រកាច់ (Convulsion)<br>- សន្លប់ (Coma)<br>- រលាក ឬហូរឈាមធ្ងន់ធ្ងរ (Severe burn or Hemorrhage)<br>- ពស់ចឹក (Snake Bite)<br>- ការពុល/ការលាងក្រពះ(Intoxication with Gastric Lavage)<br>- គ្រោះថ្នាក់ចរាចរណ៍(ករណីធ្ងន់ធ្ងរដែលត្រូវការតាមដាននៅមន្ទីរពេទ្យឬសម្រាកពេទ្យ)<br>- ស្ថានភាពវេជ្ជសាស្ត្រផ្សេងទៀត ដែលត្រូវការសេវាសង្គ្រោះបន្ទាន់។ | |
| 10 | MED1 | ករណីជំងឺទូទៅមនុស្សពេញវ័យកំរិត CPA1 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រដែលចាំបាច់សម្រាប់មនុស្សពេញវ័យផ្តល់ដោយផ្នែកជំងឺទូទៅនៅមន្ទីរពេទ្យបង្អែកកម្រិត១ ។ ករណីសម្រាកពេទ្យផ្នែកសល្យសាស្ត្រដែលមិនត្រូវការសង្គ្រោះបន្ទាន់ ឬបញ្ជូនដូចជារលាកខ្លើង ឬរបួស ត្រូវចាត់ចូលក្នុងប្រភេទករណីនេះ។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ (Severe Bronchitis)<br>- ជំងឺហឺត ( Asthma )<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត (Pulmonary Abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or Chronic | ៨០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | Diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផ្តល់ផលវិបាក (Severe/Complicated Malaria)<br>- ជំងឺរបេង/ឃ្លង់ ដែលមានផលវិបាក (Complicated Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀន(Typhoid Fever)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺរលាកក្រពះ (Gastritis)<br>- ជំងឺដំបៅក្រពះ (Gastric Ulcer)<br>- ជំងឺបេះដូង (Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ជំងឺទឹកនោមផ្អែម ( Diabetes Mellitus )<br>- ជំងឺលើសឈាម (Hypertension)<br>- ជំងឺសន្លាក់(Arthropathy)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ។ | |
| 11 | DEL1 | ករណីសំរាលកូនកំរិត CPA1 | ជាការសំរាល និងសេវាចាំបាច់ដទៃទៀតរួមមាន៖<br>- ការបញ្ចូលសេរ៉ូម<br>- ការចាក់ថ្នាំ Oxytocin ជាចំណែកមួយ | - ការសំរាលធម្មតា( Normal Delivery)<br>- ការសំរាលពិបាកដែលមិនត្រូវការវះកាត់យកកូនចេញ។ | ៨៨.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | នៃការគ្រប់គ្រងការសំរាលសកម្ម ដំណាក់កាលទី៣(AMTSL)<br>- ការបូមយកកូន<br>- ការដេរស្នាមកាត់ ឬដាច់ទ្វារមាស<br>- ការជួសជុលមាត់ស្បូនរហែកឡើងវិញ<br>- ការថែទាំ និងសង្គ្រោះទារក នៅពេលកើតភ្លាម<br>- ការថែទាំ និងតាមដានក្រោយសំ-រាល សម្រាប់ការសំរាលធម្មតា ឬមានផលវិបាកនៅមន្ទីរពេទ្យបង្អែកកម្រិត១។ | | |
| 12 | GYN1 | ករណីរោគស្ត្រី កំរិត CPA1 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រដែលចាំបាច់ផ្តល់ដោយផ្នែកសម្ភព/រោគស្ត្រី នៅមន្ទីរពេទ្យបង្អែកកម្រិត១។ | - រលាកមាត់ស្បូនធ្ងន់ធ្ងរ(Severe Cervicitis)<br>- គ្រោះថ្នាក់រហែកទ្វារមាស (Vagina Wound or Injury)។ | ៩២.០០០ |
| 13 | ABO1 | ករណីរលូត/រំលូតកូនកំរិត CPA1 | ការរំលូតកូនស្របច្បាប់ និងសេវាចាំបាច់សំរាប់ការរំលូតដោយ សុវត្ថិភាព ព្រមទាំងការថែទាំ ក្រោយរំលូត/រលូតកូនដោយឯកឯង នៅមន្ទីរពេទ្យបង្អែក | - រលូតកូន (Miscarriage)<br>- កូនស្លាប់ក្នុងពោះ (Still Birth)<br>- ការពពោះដែលមិនតាមបំណងប្រាថ្នា ឬការពពោះដែលមិនសមស្របតាមផ្នែក | ៨០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | កម្រិត១។ | វេជ្ជសាស្ត្រ។ | |
| 14 | PED1 | ករណីជំងឺទូទៅកុមារកំរិត CPA1 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់កុមារ ផ្តល់ដោយផ្នែកជំងឺកុមារនៅមន្ទីរពេទ្យបង្អែកកម្រិត១។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ (Severe Bronchitis)<br>- ជំងឺហឺត (Asthma)<br>- ទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត(Pulmonary Abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or Chronic Diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរ ឬផ្តល់ផលវិបាក ( Severe/Complicated Malaria )<br>- ជំងឺរបេង/ឃ្លង់ ដែលមានផលវិបាក (Complicated Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀន (Typhoid Fever)<br>- ជំងឺគ្រុនឈាម (Dengue Fever)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺបេះដូង (Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ។ | ៧២.០០០ |

| | | | | | |
|---|---|---|---|---|---|
| 15 | TUB1 | ករណីជំងឺរបេងកំរិត CPA1 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ត្រូវផ្តល់ដោយផ្នែកជំងឺរបេងនៅមន្ទីរពេទ្យបង្អែកកម្រិត១។ | - គ្រប់ទំរង់នៃជំងឺរបេងសួត (All Forms of Pulmonary Tuberculosis)<br>- ជំងឺរបេងក្រៅសួត (Extra-Pulmonary Tuberculosis)<br>- លើកលែងតែរលាកស្រោមខួរក្បាលដោយមេរោគរបេង (Tuberculous Meningitis) របេងសួតទំរង់ធ្ងន់ធ្ងរ (Miliary Tuberculosis) ជំងឺឃ្លង់(Leprosy)ដែលត្រូវការសម្រាកពេទ្យ។ | ១៦០.០០០ |
| 16 | CON2 | ករណីពិគ្រោះជំងឺក្រៅកំរិត CPA2 | ជាការពិគ្រោះជំងឺក្រៅករណីថ្មី និងករណីបន្តបន្ទាប់ រួមទាំងការពិគ្រោះបញ្ជូន និងការពិគ្រោះឯកទេសកំរិតមូលដ្ឋាន នៅមន្ទីរពេទ្យបង្អែកកម្រិត២។ សេវាពិគ្រោះរួមមាន៖<br>- ការសាកសួរ<br>- ការពិនិត្យ<br>- ការអប់រំសុខភាព<br>- ការប្រឹក្សាយោបល់<br>- ការផ្តល់សៀវភៅសុខភាព<br>- ការផ្តល់សេវាអមវេជ្ជសាស្ត្រ(សេវា | - ជំងឺផ្តាសសាយទូទៅ (Common Cold)<br>- ជំងឺផ្លូវដង្ហើមស្រួចស្រាវដែលគ្មានផលវិបាក(Uncomplicated Acute Respiratory Infection)<br>- ជំងឺរាគដែលមិនបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (Diarrhea without Severe Dehydration)<br>- ជំងឺគ្រុនចាញ់ដែលគ្មានផលវិបាក (Uncomplicated Malaria)<br>- ជំងឺរបេងនិងឃ្លង់ដែលគេសង្ស័យនិងគ្មានផលវិបាក(Suspected and Uncomplicated Tuberculosis/leprosy) | ១២.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | មន្ទីរពិសោធន៍ អេកូសាស្ត្រ ការថតកាំរស្មីអិច ការវាស់អគ្គិសនីបេះដូង<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញអោយប្រើ)<br>- សេវាបញ្ជូនបន្ទាន់សម្រាប់អ្នកជំងឺក្រៅ ត្រូវបានបញ្ចូលទៅក្នុងប្រភេទករណីនេះ (ដោយមិនគិតថ្លៃសេវាដឹកជញ្ជូនតាមរថយន្តគិលានសង្គ្រោះ ឬតាមមធ្យោបាយផ្សេងទេ)។ | - ជំងឺគ្រុនពោះវៀនដែលធ្វើរោគវិនិច្ឆ័យបានទាន់ពេលវេលា (Early Detection of Typhoid Fever)<br>- ជំងឺគ្រុនឈាម (Dengue Fever)<br>- ជំងឺភ្នែកក្រហមស្រួចស្រាវ ( Acute Conjunctivitis)<br>- ជំងឺរលាកត្រចៀកកណ្តាល (Otitis Media)<br>- ជំងឺពុកធ្មេញ ( Dental Caries )<br>- ជំងឺដង្កូវពោះវៀន (Intestinal Parasites)<br>- ជំងឺកាមរោគ (Sexual Transmitted Disease)<br>- ឈឺក្បាល អស់កម្លាំង ក្តៅខ្លួនដោយមិនដឹងមូលហេតុ (Headache, Fatigue, Fever...of Unknown Origin)<br>- ជំងឺទឹកនោមផ្អែម (Diabetes Mellitus )<br>- ជំងឺអេដស៍ (អ្នកជំងឺដែលទទួលនូវថ្នាំប្រឆាំង និងមេរោគអេដស៍ OI/ART) ( HIV/AIDS ambulatory OI/ART)<br>- ជំងឺផ្លូវចិត្ត ( Mental illness )<br>- បញ្ហាសុខភាពមាត់ធ្មេញ (Oral Health | |

| | | | | | |
|---|---|---|---|---|---|
| | | | | problem)<br>- ស្ថានភាពវេជ្ជសាស្ត្រផ្សេងៗទៀត ដែលមិនអាចព្យាបាលនៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យបង្អែកកំរិត១ ប៉ុន្តែមិនចាំបាច់សម្រាកពេទ្យ។<br>- ករណីបញ្ជូនបន្ទាន់គឺសំដៅលើរាល់ស្ថានភាពវេជ្ជសាស្ត្រ ដូចមានចែងក្នុងប្រភេទករណី EMG2 ដែលត្រូវការបញ្ជូនបន្ទាន់។ | |
| 17 | MIN2 | ករណីវះកាត់តូចកំរិត CPA2 | ជាសកម្មភាពវះកាត់តូចមិនសម្រាកពេទ្យ ដែលរួមមាន៖<br>- ការចាក់ថ្នាំស្ពឹក(Local Anesthesia)<br>- ការវះកាត់<br>- ការបង្ហូរខ្ទុះ(Drainage)<br>- ការលាងសំអាត<br>- ការដេររបួស<br>- ការរុំរបួស<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញអោយប្រើ)<br>- សេវាចាំបាច់ដទៃទៀតសម្រាប់ករណីសល្យសាស្ត្រតូចនៅមន្ទីរ | - បូសធម្មតា (Cutaneous Abscess)<br>- អាប់សែរាក់ៗ(Superficial Abscess )<br>- របួសតូច (Small wound)<br>- រលាកស្រាល/មធ្យម (Mild/Moderate Burn )<br>- រលាកសាច់ដុំ (Myositis)<br>- ដុំពកជាទឹក(គីសស្បែក) (Sebaceous Cyst)<br>- ដុំពកជាខ្លាញ់ (Lipoma)<br>- ការវះកាត់ស្បែកនៅចុងលិង្គ (Phymosis or Paraphymosis Circumcision)<br>- ការដកធ្មេញ (Tooth Extraction)។ | ២០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | ពេទ្យបង្អែកកម្រិត២។ | | |
| 18 | EMG2 | ករណីសង្គ្រោះបន្ទាន់កំរិត CPA2 | ជាអន្តរាគមន៍(វេជ្ជសាស្ត្រនិងអមវេជ្ជសាស្ត្រ) សង្គ្រោះជីវិត ឬអវៈយវៈណាមួយនៃសរីរាង្គរបស់អ្នកជំងឺ ឬជនរងគ្រោះ ដែលចាំបាច់ផ្តល់ដោយផ្នែកសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យបង្អែកកម្រិត២ដោយសំរាកពេទ្យ។ | គ្រប់ស្ថានភាពវេជ្ជសាស្ត្រ/ជំងឺទាំងអស់ដែលត្រូវការសេវាសង្គ្រោះបន្ទាន់រួមមានៈ<br>- ករណីលង់ទឹក (Drown)<br>- វិបត្តិដង្ហើម (Respiratory Distress )<br>- ស្តុក (Shock)<br>- ការប្រកាច់ (Convulsion)<br>- សន្លប់ (Coma)<br>- រលាក ឬហូរឈាមធ្ងន់ធ្ងរ (Severe burn or Hemorrhage)<br>- ពស់ចឹក (Snake Bite)<br>- ការពុល/ការលាងក្រពះ(Intoxication with Gastric Lavage)<br>- គ្រោះថ្នាក់ចរាចរណ៍ (ករណីធ្ងន់ធ្ងរដែលត្រូវការតាមដាននៅមន្ទីរពេទ្យ និងសម្រាកពេទ្យ )<br>- ជំងឺលើសឈាមមានផលវិបាក ឬ គ្រោះថ្នាក់ដាច់/ស្ទះសរសៃឈាមខួរក្បាល (Hypertension with Complication/Stroke)<br>- ចុកទ្រូងធ្ងន់ធ្ងរ (Severe Chest Pain) | ២០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺតេតាណូស (Tetanus)<br>- ជំងឺហើមសួតស្រួចស្រាវ (Acute Pulmonary Edema)<br>- ស្ថានភាពវេជ្ជសាស្ត្រផ្សេងទៀតដែលត្រូវការសេវាសង្គ្រោះបន្ទាន់ ។ | |
| 19 | SUR2 | ករណីសល្យសាស្ត្រកំរិត CPA2 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ផ្តល់ដោយផ្នែកសល្យសាស្ត្រ(លើកលែងករណីវះកាត់ធំដូចមានចែងក្នុង MAJ2) នៅមន្ទីរពេទ្យបង្អែកកម្រិត២។ | - ការប៉ះទង្គិចក្បាល (Head Trauma)<br>- ការប៉ះទង្គិចពោះ (Abdominal Trauma)<br>- ការប៉ះទង្គិចទ្រូង (Chest Trauma)<br>- របួសហូរឈាមក្នុងពោះ ( Intra-abdominal Hemorrhage )<br>- ជំងឺបូសថ្លើម ( Liver Abscess)<br>- គ្រួសក្នុងតំរងនោម (Kidney Stone)<br>- គ្រួសក្នុងផ្លោកនោម (Bladder Stone)<br>- គ្រួសក្នុងថង់ទឹកប្រម៉ាត់(Gallbladder Stone)។ | ១២០.០០០ |
| 20 | MAJ2 | ករណីវះកាត់ធំកំរិត CPA2 | ជាអន្តរាគមន៍សល្យសាស្ត្រធំ ធ្វើនៅក្នុងបន្ទប់វះកាត់ ដោយប្រើថ្នាំសណ្តំទូទៅ (ថ្នាំសន្លប់) ឬថ្នាំស្ពឹកតាមឆ្អឹងខ្នង ឬថ្នាំស្ពឹកនៅនឹងកន្លែងទូលាយជាពិសេស ការវះកាត់សង្គ្រោះបន្ទាន់ និងការថែទាំ/សង្គ្រោះមុន និងក្រោយវះកាត់ ដោយរួម | - ជំងឺរលាកខ្នែងពោះវៀន (Appendicitis)<br>- ជំងឺក្លូន (Hernia)<br>- កូនក្រៅស្បូន (Ectopic Pregnancy)<br>- គីស/ដុំអូវែ (Ovarian Cyst/Tumor)<br>- កាត់អវៈយវៈ (Amputation)<br>- វះកាត់ភ្នែក ( ភ្នែកឡើងបាយ ភ្នែករបួស ) | ២៤០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | ទាំងការបញ្ចូលឈាមនៅក្នុងមន្ទីរពេទ្យបង្អែកកម្រិត២។ | (Ophthalmic Surgery including Cataract, Eye Injury )<br>- វះកាត់យកកូនចេញ(ករណីសំរាលតាមទ្វារមាសមិនបាន) ( Caesarian Section)<br>- ភ្លាត់សន្លាក់ (Dislocation of Joint)<br>- ការវះកាត់បង្ការកំណើតអចិន្ត្រៃយ៍ (ចងដៃស្បូន/ចងបំពង់មេជីវិតបុរស) (Sterilization by tuboligation / vasectomy)។ | |
| 21 | MED2 | ករណីជំងឺទូទៅមនុស្សពេញវ័យកំរិត CPA2 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់មនុស្សពេញវ័យផ្តល់ដោយផ្នែកជំងឺទូទៅ នៅមន្ទីរពេទ្យបង្អែកកម្រិត២។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ(Severe Bronchitis)<br>- ជំងឺហឺត (Asthma)<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត ( Pulmonary Abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or Chronic Diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផ្តល់ផលវិបាក (Severe/Complicated Malaria)<br>- ជំងឺរបេង/ឃ្លង់ដែលមានផលវិបាក | ១០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | (Complicated Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀន (Typhoid Fever)<br>- ជំងឺរលាកស្រោមខួរក្បាល (Meningitis)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺរលាកក្រពះ (Gastritis)<br>- ជំងឺដំបៅក្រពះ ( Gastric Ulcer)<br>- ជំងឺរលាកស្រោមបេះដូងនិងជំងឺបេះដូងផ្សេងៗ (Pericarditis and Other forms of Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ជំងឺតេតាណូស (Tetanus)<br>- ជំងឺទឹកនោមផ្អែម (Diabetes Mellitus )<br>- ជំងឺលើសឈាម (Hypertension)<br>- ជំងឺសន្លាក់ (Arthropathy)<br>- ជំងឺក្រពេញទីរ៉ូអ៊ីត (Thyroid Gland Disease)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ។ | |
| 22 | DEL2 | ករណីសំរាលកូនកំរិត CPA2 | ជាការសំរាល និងសេវាចាំបាច់ដទៃទៀតរួមមាន៖<br>- ការបញ្ចូលសេរ៉ូម | - ការសំរាលកូនធម្មតា(Normal Delivery)<br>- ការសំរាលកូនពិបាកដែលមិនត្រូវការវះកាត់យកកូនចេញ។ | ១០០.០០០ |



១៥

| | | | | | |
|---|---|---|---|---|---|
| | | | - ការចាក់ថ្នាំ Oxytocin ជាចំណែកមួយនៃការគ្រប់គ្រងការសំរាលសកម្មដំណាក់កាលទី៣ (AMTSL)<br>- ការបូមយកកូន និងការប្រើសំភារៈជំនួយការសំរាលផ្សេងទៀត<br>- ការដេរស្នាមកាត់ ឬដាច់ទ្វារមាស<br>- ការជួសជុលមាត់ស្បូនរហែកឡើងវិញ<br>- ការថែទាំ និងសង្គ្រោះទារកនៅពេលកើតភ្លាម<br>- ការថែទាំនិងតាមដានក្រោយសំរាលសម្រាប់ការសំរាលធម្មតា ឬ មានផលវិបាកនៅមន្ទីរពេទ្យបង្អែកកម្រិត២។ | | |
| 23 | GYN2 | ករណីរោគស្ត្រីកំរិត CPA2 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ផ្តល់ដោយផ្នែកសម្ភព/រោគស្ត្រី នៅមន្ទីរពេទ្យបង្អែកកម្រិត២។ | - រលាកមាត់ស្បូនធ្ងន់ធ្ងរ(Severe Cervicitis)<br>- គ្រោះថ្នាក់រហែកទ្វារមាស (Vagina Wound/Injury)។ | ១២០.០០០ |
| 24 | ABO2 | ករណីរលូត/រំលូតកូនកំរិត CPA2 | ការរំលូតកូនស្របច្បាប់ និងសេវាចាំបាច់សំរាប់ការរំលូតដោយសុវត្ថិភាព ព្រមទាំង | - រលូតកូន (Miscarriage )<br>- កូនស្លាប់ក្នុងពោះ (Still Birth) | ៨០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | ការថែទាំក្រោយរំលូត/រលូតកូនដោយឯកឯងនៅមន្ទីរពេទ្យបង្អែកកម្រិត២។ | - ការពពោះដែលមិនតាមបំណងប្រាថ្នាឬការពពោះដែលមិនសមស្របតាមផ្នែកវេជ្ជសាស្ត្រ ។ | |
| 25 | PED2 | ករណីជំងឺទូទៅកុមារកំរិត CPA2 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់កុមារ ផ្តល់ដោយផ្នែកជំងឺកុមារនៅមន្ទីរពេទ្យបង្អែកកម្រិត២ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ (Severe Bronchitis)<br>- ជំងឺហឺត (Asthma)<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion )<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត (Pulmonary Abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or Chronic Diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផ្តល់ផលវិបាក (Severe/Complicated Malaria)<br>- ជំងឺរបេង/ឃ្លង់ដែលមានផលវិបាក (Complicated Tuberculosis/ leprosy )<br>- ជំងឺគ្រុនពោះវៀន (Typhoid Fever)<br>- ជំងឺគ្រុនឈាម (Dengue Fever)<br>- ជំងឺរលាកស្រោមខួរក្បាល (Meningitis)<br>- ជំងឺរលាកខួរក្បាល (Encephalitis)<br>- ជំងឺអេដស៍ (HIV/AIDS) | ៨៨.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺបេះដូង (Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម(Septicemia)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ ។ | |
| 26 | TUB2 | ករណីជំងឺរបេងកំរិត CPA2 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ត្រូវផ្តល់ដោយផ្នែកជំងឺរបេងនៅមន្ទីរពេទ្យបង្អែកកម្រិត២។ | - គ្រប់ទំរង់នៃជំងឺរបេងសួត (All Forms of Pulmonary Tuberculosis)<br>- ជំងឺរបេងក្រៅសួត (Extra-pulmonary Tuberculosis)<br>- លើកលែងតែទំរង់ជំងឺរបេងស៊ាំនឹងថ្នាំច្រើនមុខ ជំងឺឃ្លង់ដែលត្រូវការសម្រាកពេទ្យ។ | ១៨០.០០០ |
| 27 | CON3 | ករណីពិគ្រោះជំងឺក្រៅកំរិត CPA3 | ជាការពិគ្រោះជំងឺក្រៅករណីថ្មី និងករណីបន្តបន្ទាប់រួមទាំងការពិគ្រោះបញ្ជូន និងការពិគ្រោះឯកទេសគ្រប់កំរិតនៅមន្ទីរពេទ្យបង្អែកកម្រិត៣ សេវាពិគ្រោះរួមមាន៖<br>- ការសាកសួរ<br>- ការពិនិត្យ<br>- ការអប់រំសុខភាព<br>- ការប្រឹក្សាយោបល់<br>- ការផ្តល់សៀវភៅសុខភាព | - ជំងឺផ្តាសសាយទូទៅ (Common Cold )<br>- ជំងឺផ្លូវដង្ហើមស្រួចស្រាវ ដែលគ្មានផលវិបាក (Uncomplicated Acute Respiratory Infection)<br>- ជំងឺរាគដែលមិនបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (Diarrhea without Severe Dehydration)<br>- ជំងឺគ្រុនចាញ់ដែលគ្មានផលវិបាក (Uncomplicated Malaria)<br>- ជំងឺរបេងនិងឃ្លង់ដែលគេសង្ស័យនិងគ្មានផលវិបាក (Suspected and Uncomplicated | ១៦.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | - ការផ្តល់សេវាអមវេជ្ជសាស្ត្រ(សេវាមន្ទីរពិសោធន៍ អេកូសាស្ត្រ ការថតកាំរស្មីអិច ការវាស់អគ្គិសនីបេះដូង អេកូបេះដូង)<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញអោយប្រើ)។<br>- សេវាអមវេជ្ជសាស្ត្រដែលមានតំលៃខ្ពស់ ដូចជា CT-Scan, MRI, EEG មិនគិតរួមបញ្ចូលក្នុងករណីនេះទេ។ | Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀនដែលធ្វើរោគវិនិច្ឆ័យបានទាន់ពេលវេលា (Early Detection of Typhoid Fever)<br>- ជំងឺគ្រុនឈាម (Dengue Fever)<br>- ជំងឺភ្នែកក្រហមស្រួចស្រាវ (Acute Conjunctivitis)<br>- ជំងឺរលាកត្រចៀកកណ្តាល (Otitis Media)<br>- ជំងឺពុកធ្មេញ (Dental Caries)<br>- ជំងឺដង្កូវពោះវៀន (Intestinal Parasites)<br>- ជំងឺកាមរោគ(Sexual Transmitted Disease)<br>- ឈឺក្បាល អស់កម្លាំង ក្តៅខ្លួនដោយគ្មានមូលហេតុ (Headache , Fatigue ,Fever… of Unknown Origin)<br>- ជំងឺទឹកនោមផ្អែម ( Diabetes Mellitus )<br>- ជំងឺអេដស៍(អ្នកជំងឺដែលទទួលនូវថ្នាំប្រឆាំងនិងមេរោគអេដស៍ OI/ART) ( HIV/AIDS Ambulatory OI/ART)<br>- ជំងឺផ្លូវចិត្ត ( Mental illness )<br>- ជំងឺផ្សេងៗទៀតដែលមិនអាចពិគ្រោះ | |

| | | | | | |
|---|---|---|---|---|---|
| | | | | ព្យាបាលនៅថ្នាក់ក្រោមបាន គិតទាំងការថែទាំជំងឺឯកទេសគ្រប់ប្រភេទផ្នែកទន្តសាស្ត្រ ចក្ខុសាស្ត្រ ត្រចៀក/ច្រមុះ/បំពង់ក និងផ្លូវចិត្ត ប៉ុន្តែមិនចាំបាច់សម្រាកពេទ្យ ។ | |
| 28 | MIN3 | ករណីវះកាត់តូច កំរិត CPA3 | ជាសកម្មភាពវះកាត់តូចមិនសម្រាកពេទ្យ ដែលរួមមាន៖<br>- ការចាក់ថ្នាំស្ពឹក(Local Anesthesia )<br>- ការវះកាត់<br>- ការបង្ហូរខ្ទុះ(Drainage)<br>- ការលាងសំអាត<br>- ការដេររបួស<br>- ការរុំរបួស<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញអោយប្រើ)<br>- សេវាចាំបាច់ដទៃទៀតសម្រាប់ករណីសល្យសាស្ត្រតូចនៅមន្ទីរពេទ្យបង្អែកកម្រិត៣ ។ | - បូសធម្មតា (Cutaneous Abscess)<br>- អាប់សែរាក់ៗ (Superficial Abscess)<br>- របួសតូចតាច (Small Wound)<br>- រលាកស្រាល/មធ្យម(Mild/Moderate Burn)<br>- រលាកសាច់ដុំ (Myositis)<br>- គីសស្បែក (Sebaceous Cyst)<br>- ដុំខ្លាញ់ (Lipoma)<br>- ការវះកាត់ស្បែកនៅចុងលិង្គ(ស្បែកបាំងចុងប្រដាប់ភេទបុរសទាំងមូលឬមួយផ្នែក) (Phymosis or Paraphymosis Circumcision)<br>- ការដកធ្មេញ (Tooth Extraction )។ | ២៨.០០០ |
| 29 | EMG3 | ករណីសង្គ្រោះបន្ទាន់កំរិត CPA3 | ជាអន្តរាគមន៍(វេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ) សង្គ្រោះជីវិត ឬអវៈយវៈណា | គ្រប់ស្ថានភាពវេជ្ជសាស្ត្រ/ជំងឺទាំងអស់ដែលត្រូវការសេវាសង្គ្រោះបន្ទាន់រួមមាន៖ | ២៨០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | មួយនៃសរីរាង្គរបស់អ្នកជំងឺ ឬជនរងគ្រោះ ដែលចាំបាច់ផ្តល់ដោយផ្នែកសង្គ្រោះបន្ទាន់ នៅមន្ទីរពេទ្យបង្អែកកម្រិត៣ ដោយសំរាកពេទ្យ។ | - ករណីលង់ទឹក (Drown )<br>- វិបត្តិដង្ហើម (Respiratory Distress)<br>- ស្ហុក (Shock)<br>- ការប្រកាច់ (Convulsion)<br>- សន្លប់ (Coma)<br>- រលាកឬហូរឈាមធ្ងន់ធ្ងរ (Severe Burn or Hemorrhage)<br>- ពស់ចឹក (Snake Bite)<br>- ការពុល/ការលាងក្រពះ( Intoxication with Gastric Lavage)<br>- គ្រោះថ្នាក់ចរាចរណ៍ (ករណីធ្ងន់ធ្ងរដែលត្រូវការតាមដាននៅមន្ទីរពេទ្យ និងសម្រាកពេទ្យ)<br>- ជំងឺលើសឈាមមានផលវិបាក ឬ គ្រោះថ្នាក់ដាច់ ឬ ស្ទះសរសៃឈាមខួរក្បាល (Hypertension with Complication/Stroke)<br>- ចុកទ្រូងធ្ងន់ធ្ងរ (Severe Chest Pain)<br>- ជំងឺតេតាណូស (Tetanus )<br>- ជំងឺហើមសួតស្រួចស្រាវ ( Acute Pulmonary Edema) | |

| | | | | | |
|---|---|---|---|---|---|
| | | | | - ស្ថានភាពវេជ្ជសាស្ត្រផ្សេងទៀតដែលត្រូវការសេវាសង្គ្រោះបន្ទាន់។ | |
| 30 | SUR3 | ករណីសល្យសាស្ត្រកំរិត CPA3 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ផ្តល់ដោយផ្នែកសល្យសាស្ត្រ (លើកលែងករណីវះកាត់ធំដូចមានចែងក្នុងMAJ3) នៅមន្ទីរពេទ្យបង្អែកកម្រិត៣ ។ | - ការប៉ះទង្គិចក្បាល (Head Trauma)<br>- ការប៉ះទង្គិចពោះ (Abdominal Trauma)<br>- ការប៉ះទង្គិចទ្រូង (Chest Trauma)<br>- របួសហូរឈាមក្នុងពោះ(Intra-abdominal Hemorrhage)<br>- បូសថ្លើម (Liver Abscess)<br>- គ្រួសក្នុងតំរងនោម (Kidney Stone)<br>- គ្រួសក្នុងផ្លោកនោម (Bladder Stone)<br>- គ្រួសក្នុងថង់ទឹកប្រម៉ាត់(Gallbladder Stone)។ | ១៦០.០០០ |

| | | | | | |
|---|---|---|---|---|---|
| 31 | MAJ3 | ករណីវះកាត់ធំកំរិត CPA3 | ជាអន្តរាគមន៍សល្យសាស្ត្រធំធ្វើនៅក្នុងបន្ទប់វះកាត់ ដោយប្រើថ្នាំសណ្តំទូទៅ (ថ្នាំសន្លប់) ឬថ្នាំស្ពឹកតាមឆ្អឹងខ្នង ឬថ្នាំស្ពឹកនៅនឹងកន្លែងទូលាយជាពិសេស ការវះកាត់សង្គ្រោះបន្ទាន់ និងការថែទាំ/សង្គ្រោះមុន និងក្រោយវះកាត់ដោយរួមទាំងការបញ្ចូលឈាមនៅក្នុងមន្ទីរពេទ្យបង្អែកកម្រិត៣ ។ | - ជំងឺរលាកខ្នែងពោះវៀនគិតទាំងអាប់សែខ្នែងពោះវៀន (Appendicitis Including Appendicular Abscess)<br>- ជំងឺក្លូន(គិតទាំងក្លូនចុក) (Hernia including Complicated or Strangulated)<br>- កូនក្រៅស្បូន (Ectopic Pregnancy)<br>- គីស/ដុំអូវែ (Ovarian Cyst/Tumor )<br>- រលាកស្រោមពោះ (Peritonitis)<br>- ការវះកាត់តំរងនោម (គ្រោះក្នុងតំរងនោម ឬជំងឺតំរងនោមដោយមូលហេតុផ្សេងៗ) (Renal Surgery including Kidney stone or other causes)<br>- ការវះកាត់ក្រពេញប្រូស្តាត(ដំពក ឬមហារីកប្រូស្តាត) (Prostate Gland Surgery including Prostate Tumor Or Cancer)<br>- ការវះកាត់ប្លោកនោម (គ្រោះក្នុងប្លោកនោម ឬ មូលហេតុផ្សេងៗទៀតដែលនាំអោយមានជំងឺប្លោកនោម) (Bladder Surgery including Bladder stone or | ៤០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | other causes)<br>- ការវះកាត់ថង់ទឹកប្រមាត់(គ្រោះក្នុងថង់ទឹកប្រមាត់ ឬ មូលហេតុផ្សេងៗទៀតដែលនាំអោយមានជំងឺថង់ទឹកប្រមាត់) (Gallbladder Surgery including Gallbladder Stone and Other causes)<br>- ការវះកាត់ស្បូន ( ការធ្លាយស្បូន ជំងឺស្រុតស្បូន ដុំសាច់ស្បូន) (Uterus Surgery including Uterus Rupture, Prolapse, Tumor)<br>- ការវះកាត់ដុំពោះ (Abdominal Tumor Surgery)<br>- ការវះកាត់ក្រពេញទីរ៉ូអ៊ីត(ជំងឺក្រពេញទីរ៉ូអ៊ីតមានផលវិបាក) (Thyroid Gland Surgery including Complicated Thyroid disease)<br>- ការវះកាត់ពោះវៀន ( ការស្ទះពោះវៀន , របួសពោះវៀន) (Intestinal Surgery including Intestinal Occlusion, Intestinal Injury)<br>- ការវះកាត់អវៈយវៈ ឬការវះកាត់ឆ្អឹងផ្សេង | |

| | | | | | |
|---|---|---|---|---|---|
| | | | | ទៀត(ការបាក់ឆ្អឹង) (Amputation and other Orthopedic Surgical interventions (Bone Fracture)<br>- ការវះកាត់ភ្នែក(ភ្នែកឡើងបាយ រហូសភ្នែក) (Ophthalmic Surgery including Cataract, Eye Injury)<br>- ការវះកាត់យកកូនចេញ (Caesarian Section)<br>- ការវះកាត់ធំផ្នែកត្រចៀក/ច្រមុះ/បំពង់ក ( E-N-T Major Surgery )<br>- ការវះកាត់បង្ការកំណើតអចិន្ត្រៃយ៍ (ចងដៃស្បូន ចងបំពង់មេជីវិតបុរស) (Sterilization by Tuboligation/Vasectomy)។ | |
| 32 | MED3 | ករណីជំងឺទូទៅមនុស្សពេញវ័យកំរិត CPA3 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់មនុស្សពេញវ័យផ្តល់ដោយផ្នែកជំងឺទូទៅនៅមន្ទីរពេទ្យបង្អែកកម្រិត៣ ។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ (Severe Bronchitis)<br>- ជំងឺហឺត (Asthma)<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត (Pulmonary Abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or Chronic Diarrhea) | ១២០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផ្តល់ផលវិបាក (Severe/Complicated Malaria)<br>- ជំងឺរបេង/ឃ្លង់ ដែលមានផលវិបាក (Complicated Tuberculosis/Leprosy)<br>- ជំងឺគ្រុនពោះវៀន (Typhoid Fever)<br>- ជំងឺរលាកស្រោមខួរក្បាល (Meningitis)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺរលាកក្រពះ (Gastritis)<br>- ជំងឺដំបៅក្រពះ (Gastric Ulcer )<br>- ហូរឈាមខាងក្នុងពោះ (Intra-abdominal Hemorrhage)<br>- ជំងឺរលាកស្រោមបេះដូង និងជំងឺបេះដូងផ្សេងៗ (Pericarditis and Other Forms of Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ជំងឺតេតាណូស (Tetanus)<br>- ជំងឺទឹកនោមផ្អែម (Diabetes Mellitus)<br>- ជំងឺលើសឈាម (Hypertension)<br>- ជំងឺសន្លាក់ (Arthropathy)<br>- ជំងឺក្រពេញទីរ៉ូអ៊ីត(Thyroid Gland Disease) | |

| | | | | | |
|---|---|---|---|---|---|
| | | | | - ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ។ | |
| 33 | DEL3 | ករណីសំរាលកូនកំរិត CPA3 | ជាការសំរាលកូននិងសេវាចាំបាច់ដទៃទៀតរួមមានៈ<br>- ការបញ្ចូលសេរ៉ូម<br>- ការចាក់ថ្នាំ Oxytocin ជាចំណែកមួយនៃការគ្រប់គ្រងការសំរាលសកម្មដំណាក់កាលទី៣ (AMTSL)<br>- ការបូមយកកូន និងការប្រើសំភារៈជំនួយការសំរាលផ្សេងទៀត<br>- ការដេរស្នាមកាត់ ឬ ដាច់ទ្វារមាស ការជួសជុលមាត់ស្បូនរហែកឡើងវិញ<br>- ការថែទាំនិងសង្គ្រោះទារកនៅពេលកើតភ្លាម<br>- ការថែទាំនិងតាមដានក្រោយសំរាលសម្រាប់ការសំរាលធម្មតា ឬ មានផលវិបាកនៅមន្ទីរពេទ្យបង្អែកកម្រិត ៣ ។ | - ការសំរាលកូនធម្មតា (Normal delivery)<br>- ការសំរាលកូនពិបាកដែលមិនត្រូវការវះកាត់យកកូនចេញ ។ | ១២០.០០០ |

| | | | | | |
|---|---|---|---|---|---|
| 34 | GYN3 | ករណីរោគស្ត្រីកំរិត CPA3 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ផ្តល់ដោយផ្នែកសម្ភព/រោគស្ត្រីនៅមន្ទីរពេទ្យបង្អែកកម្រិត៣ ។ | - រលាកទ្វារមាសធ្ងន់ធ្ងរ (Severe Cervicitis )<br>- គ្រោះថ្នាក់របែកទ្វារមាស (Vagina Wound/Injury)<br>- ជំងឺមហារីកមាត់ស្បូន (Cervical Cancer)<br>- ជំងឺមហារីកដោះ (Breast Cancer) | ១៦០.០០០ |
| 35 | ABO3 | ករណីរលូត/រំលូតកូនកំរិត CPA3 | ការរំលូតកូនស្របច្បាប់ និងសេវាចាំបាច់សំរាប់ការរំលូតដោយសុវត្ថិភាព ព្រមទាំងការថែទាំក្រោយរំលូត/រលូតកូនដោយឯកឯងនៅមន្ទីរពេទ្យបង្អែកកម្រិត៣ ។ | - រលូតកូន (Miscarriage)<br>- កូនស្លាប់ក្នុងពោះ (Still Birth)<br>- ការពពោះដែលមិនតាមបំណងប្រាថ្នា ឬការពពោះដែលមិនសមស្របតាមផ្នែកវេជ្ជសាស្ត្រ ។ | ១០០.០០០ |
| 36 | PED3 | ករណីជំងឺទូទៅកុមារកំរិត CPA3 | ជាការសម្រាកពេទ្យសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់កុមារ ផ្តល់ជូននៅផ្នែកជំងឺកុមារនៅមន្ទីរពេទ្យបង្អែកកម្រិត៣ ។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ(Severe Bronchitis)<br>- ជំងឺហឺត (Asthma)<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត( Pulmonary Abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe Or Chronic Diarrhea) | ១០៨.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផ្ដល់ផលវិបាក (Severe/Complicated Malaria)<br>- ជំងឺរបេង/ឃ្លង់ដែលមានផលវិបាក (Complicated Tuberculosis/Leprosy)<br>- ជំងឺគ្រុនពោះវៀន (Typhoid Fever)<br>- ជំងឺគ្រុនឈាម (Dengue Fever)<br>- ជំងឺរលាកស្រោមខួរក្បាល (Meningitis)<br>- ជំងឺរលាកខួរក្បាល (Encephalitis)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺបេះដូង (Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ជំងឺតេតាណូស (Tetanus)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ ។ | |
| 37 | TUB3 | ករណីជំងឺរបេងកំរិត CPA3 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ដែលផ្ដល់ដោយផ្នែកជំងឺរបេងនៅមន្ទីរពេទ្យបង្អែកកម្រិត៣ ។ | - គ្រប់ទំរង់នៃជំងឺរបេងសួត (All forms of Pulmonary Tuberculosis)<br>- ជំងឺរបេងក្រៅសួត (Extra-pulmonary Tuberculosis)<br>- លើកលែងតែទំរង់ជំងឺរបេងស៊ាំនឹងថ្នាំច្រើនមុខ(Except Multidrug Resistant Forms) | ២០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | ជំងឺឃ្លង់(Leprosy)ដែលត្រូវការសម្រាក ពេទ្យ។ | |
| 38 | CON4 | ករណីពិគ្រោះជំងឺក្រៅកំរិត NH | ជាការពិគ្រោះជំងឺក្រៅករណីថ្មី និងករណីបន្តបន្ទាប់រួមទាំងការពិគ្រោះបញ្ជូន និងការពិគ្រោះឯកទេសគ្រប់កំរិតនៅមន្ទីរពេទ្យជាតិសេវាពិគ្រោះរួមមាន៖<br>- ការសាកសួរ<br>- ការពិនិត្យ<br>- ការអប់រំសុខភាព<br>- ការប្រឹក្សាយោបល់<br>- ការផ្តល់សៀវភៅសុខភាព<br>- ការផ្តល់សេវាអមវេជ្ជសាស្ត្រ(សេវាមន្ទីរពិសោធន៍ អេកូសាស្ត្រ ការថតកាំរស្មីអិច ការវាស់អគ្គិសនីបេះដូង អេកូបេះដូង)<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញអោយប្រើ)។<br>- សេវាអមវេជ្ជសាស្ត្រដែលមានតំលៃខ្ពស់ ដូចជា CT-Scan, MRI, EEG | - ជំងឺផ្តាសសាយទូទៅ (Common Cold )<br>- ជំងឺផ្លូវដង្ហើមស្រួចស្រាវ ដែលគ្មានផលវិបាក (Uncomplicated Acute Respiratory Infection)<br>- ជំងឺរាគដែលមិនបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (Diarrhea without Severe Dehydration)<br>- ជំងឺគ្រុនចាញ់ដែលគ្មានផលវិបាក (Uncomplicated Malaria)<br>- ជំងឺរបេងនិងឃ្លង់ដែលគេសង្ស័យនិងគ្មានផលវិបាក (Suspected and Uncomplicated Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀនដែលធ្វើរោគវិនិច្ឆ័យបានទាន់ពេលវេលា (Early Detection of Typhoid Fever)<br>- ជំងឺគ្រុនឈាម (Dengue Fever)<br>- ជំងឺភ្នែកក្រហមស្រួចស្រាវ (Acute Conjunctivitis) | ២៤.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | មិនគិតរួមបញ្ចូលក្នុងករណីនេះទេ។ | - ជំងឺរលាកត្រចៀកកណ្ដាល (Otitis Media)<br>- ជំងឺពុកធ្មេញ (Dental Caries)<br>- ជំងឺដង្កូវពោះវៀន (Intestinal Parasites)<br>- ជំងឺកាមរោគ(Sexual Transmitted Disease)<br>- ឈឺក្បាល អស់កម្លាំង ក្ដៅខ្លួនដោយគ្មានមូលហេតុ (Headache , Fatigue ,Fever… of Unknown Origin)<br>- ជំងឺទឹកនោមផ្អែម ( Diabetes Mellitus )<br>- ជំងឺអេដស៍(អ្នកជំងឺដែលទទួលនូវថ្នាំប្រឆាំងនិងមេរោគអេដស៍ OI/ART) ( HIV/AIDS Ambulatory OI/ART)<br>- ជំងឺផ្លូវចិត្ត ( Mental illness )<br>- ជំងឺផ្សេងៗទៀតដែលមិនអាចពិគ្រោះព្យាបាលនៅថ្នាក់ក្រោមបាន គិតទាំងការថែទាំជំងឺឯកទេសគ្រប់ប្រភេទផ្នែកទន្តសាស្ត្រ ចក្ខុសាស្ត្រ ត្រចៀក/ច្រមុះ/បំពង់ក និងផ្លូវចិត្ត ប៉ុន្តែមិនចាំបាច់សម្រាកពេទ្យ ។ | |
| 39 | MIN4 | ករណីវះកាត់តូចកំរិត NH | ជាសកម្មភាពវះកាត់តូចមិនសម្រាកពេទ្យ ដែលរួមមាន៖<br>- ការចាក់ថ្នាំស្ពឹក(Local Anesthesia ) | - បូសធម្មតា (Cutaneous Abscess)<br>- អាប់សែរាក់ៗ (Superficial Abscess)<br>- របួសតូចតាច (Small Wound) | ៥០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | - ការវះកាត់<br>- ការបង្ហូរខ្ទុះ(Drainage)<br>- ការលាងសំអាត<br>- ការដេររបួស<br>- ការរុំរបួស<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញអោយប្រើ)<br>- សេវាចាំបាច់ដទៃទៀតសម្រាប់ករណីសល្យសាស្ត្រតូចនៅ មន្ទីរពេទ្យជាតិ។ | - រលាកស្រាល/មធ្យម(Mild/Moderate Burn)<br>- រលាកសាច់ដុំ (Myositis)<br>- គីសស្បែក (Sebaceous Cyst)<br>- ដុំខ្លាញ់ (Lipoma)<br>- ការវះកាត់ស្បែកនៅចុងលិង្គ(ស្បែកបាំងចុងប្រដាប់ភេទបុរសទាំងមូលឬមួយផ្នែក) (Phymosis or Paraphymosis Circumcision)<br>- ការដកធ្មេញ (Tooth Extraction )។ | |
| 40 | EMG4 | ករណីសង្គ្រោះបន្ទាន់កំរិត NH | ជាអន្តរាគមន៍(វេជ្ជសាស្ត្រ និងអមវេជ្ជ-សាស្ត្រ) សង្គ្រោះជីវិត ឬអវៈយវៈណាមួយនៃសរីរាង្គរបស់អ្នកជំងឺ ឬជនរងគ្រោះដែលចាំបាច់ផ្តល់ដោយផ្នែកសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យ ជាតិ ដោយសំរាកពេទ្យ។ | គ្រប់ស្ថានភាពវេជ្ជសាស្ត្រ/ជំងឺទាំងអស់ដែលត្រូវការសេវាសង្គ្រោះបន្ទាន់រួមមាន៖<br>- ករណីលង់ទឹក (Drown )<br>- វិបត្តិដង្ហើម (Respiratory Distress)<br>- ស្តុក (Shock)<br>- ការប្រកាច់ (Convulsion)<br>- សន្លប់ (Coma)<br>- រលាកឬហូរឈាមធ្ងន់ធ្ងរ (Severe Burn or Hemorrhage) | ៦០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ពស់ចឹក (Snake Bite)<br>- ការពុល/ការលាងក្រពះ( Intoxication with Gastric Lavage)<br>- គ្រោះថ្នាក់ចរាចរណ៍ (ករណីធ្ងន់ធ្ងរដែលត្រូវការតាមដាននៅមន្ទីរពេទ្យ និងសម្រាកពេទ្យ)<br>- ជំងឺលើសឈាមមានផលវិបាក ឬ គ្រោះថ្នាក់ដាច់ ឬ ស្ទះសរសៃឈាមខួរក្បាល (Hypertension with Complication/Stroke)<br>- ចុកទ្រូងធ្ងន់ធ្ងរ (Severe Chest Pain)<br>- ជំងឺតេតាណូស (Tetanus )<br>- ជំងឺហើមសួតស្រួចស្រាវ ( Acute Pulmonary Edema)<br>- ស្ថានភាពវេជ្ជសាស្ត្រផ្សេងទៀតដែលត្រូវការសេវាសង្គ្រោះបន្ទាន់។ | |
| 41 | SUR4 | ករណីសល្យសាស្ត្រកំរិត NH | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ផ្តល់ដោយផ្នែកសល្យសាស្ត្រ (លើកលែងករណីវះកាត់ធំដូចមានចែងក្នុងMAJ4) | - ការប៉ះទង្គិចក្បាល (Head Trauma)<br>- ការប៉ះទង្គិចពោះ (Abdominal Trauma)<br>- ការប៉ះទង្គិចទ្រូង (Chest Trauma)<br>- របួសហូរឈាមក្នុងពោះ(Intra-abdominal | ៣០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | នៅ មន្ទីរពេទ្យជាតិ។ | Hemorrhage)<br>- បូសថ្លើម (Liver Abscess)<br>- គ្រួសក្នុងតំរងនោម (Kidney Stone)<br>- គ្រួសក្នុងផ្លោកនោម (Bladder Stone)<br>- គ្រួសក្នុងថង់ទឹកប្រមាត់(Gallbladder Stone)។ | |
| 42 . | MAJ4 | ករណីវះកាត់ធំ កំរិត NH | ជាអន្តរាគមន៍សល្យសាស្ត្រធំធ្វើនៅក្នុងបន្ទប់វះកាត់ ដោយប្រើថ្នាំសណ្តំទូទៅ (ថ្នាំសន្លប់) ឬថ្នាំស្ពឹកតាមឆ្អឹងខ្នង ឬថ្នាំស្ពឹកនៅនឹងកន្លែងទូលាយជាពិសេស ការវះកាត់សង្គ្រោះបន្ទាន់ និងការថែទាំ/សង្គ្រោះមុន និងក្រោយវះកាត់ដោយរួមទាំងការបញ្ចូលឈាមនៅក្នុងមន្ទីរពេទ្យជាតិ។ | - ជំងឺរលាកខ្នែងពោះវៀនគិតទាំងអាប់សែខ្នែងពោះវៀន (Appendicitis Including Appendicular Abscess)<br>- ជំងឺក្លូន(គិតទាំងក្លូនចុក) (Hernia including Complicated or Strangulated)<br>- កូនក្រៅស្បូន (Ectopic Pregnancy)<br>- គីស/ដុំអូវែ (Ovarian Cyst/Tumor )<br>- រលាកស្រោមពោះ (Peritonitis)<br>- ការវះកាត់តំរងនោម (គ្រោះក្នុងតំរងនោម ឬជំងឺតំរងនោមដោយមូលហេតុផ្សេងៗ) (Renal Surgery including Kidney stone or other causes)<br>- ការវះកាត់ក្រពេញប្រូស្តាត(ជំពក | ១.០០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | ឬមហារីកប្រូស្តាត) (Prostate Gland Surgery including Prostate Tumor Or Cancer)<br>- ការវះកាត់ប្លោកនោម (គ្រោះក្នុងប្លោកនោម ឬ មូលហេតុផ្សេងៗទៀតដែលនាំអោយមានជំងឺប្លោកនោម) (Bladder Surgery including Bladder stone or other causes)<br>- ការវះកាត់ថង់ទឹកប្រមាត់(គ្រោះក្នុងថង់ទឹកប្រមាត់ ឬ មូលហេតុផ្សេងៗទៀតដែលនាំអោយមានជំងឺថង់ទឹកប្រមាត់) (Gallbladder Surgery including Gallbladder Stone and Other causes)<br>- ការវះកាត់ស្បូន ( ការធ្លាយស្បូន ជំងឺស្រុតស្បូន ដុំសាច់ស្បូន) (Uterus Surgery including Uterus Rupture, Prolapse, Tumor)<br>- ការវះកាត់ដុំពោះ (Abdominal Tumor Surgery)<br>- ការវះកាត់ក្រពេញទីរ៉ូអ៊ីត(ជំងឺក្រពេញទីរ៉ូអ៊ី | |

| | | | | | |
|---|---|---|---|---|---|
| | | | | តមានផលវិបាក) (Thyroid Gland Surgery including Complicated Thyroid disease)<br>- ការវះកាត់ពោះវៀន ( ការស្ទះពោះវៀន , របួសពោះវៀន) (Intestinal Surgery including Intestinal Occlusion, Intestinal Injury)<br>- ការវះកាត់អវៈយវៈ ឬការវះកាត់ឆ្អឹងផ្សេងទៀត(ការបាក់ឆ្អឹង) (Amputation and other Orthopedic Surgical interventions (Bone Fracture)<br>- ការវះកាត់ភ្នែក(ភ្នែកឡើងបាយ របួសភ្នែក) (Ophthalmic Surgery including Cataract, Eye Injury)<br>- ការវះកាត់យកកូនចេញ (Caesarian Section)<br>- ការវះកាត់ធំផ្នែកត្រចៀក/ច្រមុះ/បំពង់ក ( E-N-T Major Surgery ) | |
| 43 | PRE4 | ករណីវះកាត់មធ្យមកំរិត NH | ជាអន្តរាគមន៍សល្យសាស្ត្រធ្វើនៅក្នុងបន្ទប់វះកាត់ ដោយប្រើថ្នាំសណ្ដំទូទៅ (ថ្នាំសន្លប់) ឬថ្នាំស្ពឹកតាមឆ្អឹងខ្នង ឬថ្នាំ | - ការវះកាត់បង្ការកំណើតអចិន្ត្រៃយ៍ (ចងដៃស្បូន ចងបំពង់មេជីវិតបុរស) (Sterilization by Tuboligation/Vasectomy)។ | ៨០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | ស្ដីកនៅនឹងកន្លែងទូលាយជាពិសេស ការវះកាត់សង្គ្រោះបន្ទាន់ និងការថែទាំ/សង្គ្រោះមុន និងក្រោយវះកាត់ដោយរួមទាំងការបញ្ចូលឈាមនៅក្នុងមន្ទីរពេទ្យជាតិ។ | | |
| 44 | MED4 | ករណីជំងឺទូទៅមនុស្សពេញវ័យ កំរិត NH | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់មនុស្សពេញវ័យផ្តល់ដោយផ្នែកជំងឺទូទៅនៅមន្ទីរពេទ្យជាតិ។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ (Severe Bronchitis)<br>- ជំងឺហឺត (Asthma)<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត (Pulmonary Abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or Chronic Diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផ្តល់ផលវិបាក (Severe/Complicated Malaria)<br>- ជំងឺរបេង/ឃ្លង់ ដែលមានផលវិបាក (Complicated Tuberculosis/Leprosy)<br>- ជំងឺគ្រុនពោះវៀន (Typhoid Fever)<br>- ជំងឺរលាកស្រោមខួរក្បាល (Meningitis)<br>- ជំងឺអេដស៍ (HIV/AIDS) | ៣០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺរលាកក្រពះ (Gastritis)<br>- ជំងឺដំបៅក្រពះ (Gastric Ulcer )<br>- ហូរឈាមខាងក្នុងពោះ (Intra-abdominal Hemorrhage)<br>- ជំងឺរលាកស្រោមបេះដូង និងជំងឺបេះដូងផ្សេងៗ (Pericarditis and Other Forms of Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ជំងឺតេតាណូស (Tetanus)<br>- ជំងឺទឹកនោមផ្អែម (Diabetes Mellitus)<br>- ជំងឺលើសឈាម (Hypertension)<br>- ជំងឺសន្លាក់ (Arthropathy)<br>- ជំងឺក្រពេញទីរ៉ូអ៊ីត(Thyroid Gland Disease)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ។ | |
| 45 | DEL4 | ករណីសំរាលកូនកំរិត NH | ជាការសំរាលកូននិងសេវាចាំបាច់ដទៃទៀតរួមមានៈ<br>- ការបញ្ចូលសេរ៉ូម<br>- ការចាក់ថ្នាំ Oxytocin ជាចំណែកមួយ | - ការសំរាលកូនធម្មតា (Normal delivery)<br>- ការសំរាលកូនពិបាកដែលមិនត្រូវការវះកាត់យកកូនចេញ ។ | ៤០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | នៃការគ្រប់គ្រងការសំរាលសកម្មដំណាក់កាលទី៣ (AMTSL)<br>- ការបូមយកកូន និងការប្រើសំភារៈជំនួយការសំរាលផ្សេងទៀត<br>- ការដេរស្នាមកាត់ ឬ ដាច់ទ្វារមាស ការជួសជុលមាត់ស្បូនរហែកឡើងវិញ<br>- ការថែទាំនិងសង្គ្រោះទារកនៅពេលកើតភ្លាម<br>- ការថែទាំនិងតាមដានក្រោយសំរាលសម្រាប់ការសំរាលធម្មតា ឬ មានផលវិបាកនៅ ឬមន្ទីរពេទ្យជាតិ។ | | |
| 46 | GYN4 | ករណីរោគស្ត្រីកំរិត NH | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ផ្តល់ដោយផ្នែកសម្ភព/រោគស្ត្រីនៅ មន្ទីរពេទ្យជាតិ។ | - រលាកទ្វារមាសធ្ងន់ធ្ងរ (Severe Cervicitis )<br>- គ្រោះថ្នាក់រហែកទ្វារមាស (Vagina Wound/Injury)<br>- ជំងឺមហារីកមាត់ស្បូន (Cervical Cancer)<br>- ជំងឺមហារីកដោះ (Breast Cancer) | ៣០០.០០០ |



Ha. m

| | | | | | |
|---|---|---|---|---|---|
| 47 | ABO4 | ករណីរលូត/រំលូតកូនកំរិត NH | ការរំលូតកូនស្របច្បាប់ និងសេវាចាំបាច់សំរាប់ការរំលូតដោយសុវត្ថិភាព ព្រមទាំងការថែទាំក្រោយរំលូត/រលូតកូនដោយឯកឯងនៅ មន្ទីរពេទ្យជាតិ។ | - រលូតកូន (Miscarriage)<br>- កូនស្លាប់ក្នុងពោះ (Still Birth)<br>- ការពពោះដែលមិនតាមបំណងប្រាថ្នា ឬ ការពពោះដែលមិនសមស្របតាមផ្នែកវេជ្ជសាស្ត្រ ។ | ២០០.០០០ |
| 48 | PED4 | ករណីជំងឺទូទៅកុមារកំរិត NH | ជាការសម្រាកពេទ្យសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់កុមារ ផ្តល់ជូននៅផ្នែកជំងឺកុមារនៅមន្ទីរពេទ្យជាតិ។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ(Severe Bronchitis)<br>- ជំងឺហឺត (Asthma)<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត( Pulmonary Abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe Or Chronic Diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរ ឬផ្តល់ផលវិបាក (Severe/Complicated Malaria)<br>- ជំងឺរបេង/ឃ្លង់ដែលមានផលវិបាក (Complicated Tuberculosis/Leprosy)<br>- ជំងឺគ្រុនពោះវៀន (Typhoid Fever)<br>- ជំងឺគ្រុនឈាម (Dengue Fever) | ៣០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺរលាកស្រោមខួរក្បាល (Meningitis)<br>- ជំងឺរលាកខួរក្បាល (Encephalitis)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺបេះដូង (Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ជំងឺតេតាណូស (Tetanus)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ ។ | |
| 49 | TUB4 | ករណីជំងឺរបេងកំរិត NH | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ-សាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ដែលផ្តល់ដោយផ្នែកជំងឺរបេងនៅមន្ទីរពេទ្យជាតិ។ | - គ្រប់ទំរង់នៃជំងឺរបេងសួត (All forms of Pulmonary Tuberculosis)<br>- ជំងឺរបេងក្រៅសួត (Extra-pulmonary Tuberculosis)<br>- លើកលែងតែទំរង់ជំងឺរបេងស៊ាំនឹងថ្នាំច្រើនមុខ(Except Multidrug Resistant Forms) ជំងឺឃ្លង់(Leprosy)ដែលត្រូវការសម្រាកពេទ្យ។ | ៣០០.០០០ |

*ឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រ.ក ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព*

## វិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទសេវា

ឧបសម្ព័ន្ធនេះមានគោលបំណងរៀបចំវិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទសេវា សម្រាប់ករណីពិសេសតាមតារាងតម្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ របស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ផ្នែកថែទាំសុខភាព។

**ក. វិធីសាស្ត្រនេះត្រូវអនុវត្តចំពោះប្រភេទករណីដូចមានចែងក្នុងឧបសម្ព័ន្ធទី១ ហើយដែលត្រូវការសេវាពិសេសបន្ថែម ឬសេវាព្យាបាលនិងថែទាំបន្ត និងករណីពិសេសផ្សេងទៀតដែលគ្មាននៅក្នុងឧបសម្ព័ន្ធទី១**

**ក.១ ប្រភេទករណីដូចមានចែងក្នុងឧបសម្ព័ន្ធទី១ ហើយដែលត្រូវការសេវាពិសេសបន្ថែម ឬ សេវាព្យាបាល និងថែទាំបន្តដូចខាងក្រោម៖**

**ក.១.១ ការលាងឈាម** គឺជាការលាងឈាមបណ្តាលមកពីឧបទ្ទវហេតុគ្រោះថ្នាក់ផ្សេងៗ ឬសង្គ្រោះបន្ទាន់ ។

***ចំពោះករណីលាងឈាមតាមការគ្រោងទុកដែលបណ្តាលមកពីជំងឺរ៉ាំរ៉ៃ មិនត្រូវបានរាប់បញ្ចូលឡើយ។***

**ក.១.២ MRI (Magnetic Resonance Imaging)** គឺជាបច្ចេកទេសរូបភាពវេជ្ជសាស្ត្រដែលផ្តល់ដោយមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាពទៅតាមស្ថានភាពចាំបាច់ និងមនសិការវិជ្ជាជីវៈ។

**ក.១.៣ CT SCAN** គឺជាទម្រង់រូបភាពវេជ្ជសាស្ត្រដែលផ្តល់ដោយមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាពតាមស្ថានភាពចាំបាច់ និងមនសិការវិជ្ជាជីវៈ។

**ក.១.៤ ការព្យាបាលដោយកាំរស្មីអ៊ិច (Radiotherapy)** គឺជាការព្យាបាលជំងឺមហារីកដោយកាំរស្មីអ៊ិចផ្តល់ដោយមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាពតាមបច្ចេកទេសវេជ្ជសាស្ត្រ។

**ក.១.៥ ការវិភាគរកកោសិកាមហារីក** គឺជាការវិភាគចំណិតដុំសាច់នៃសរីរាង្គឬផ្នែកណាមួយនៃរាងកាយដើម្បីរកកោសិកាមហារីក ដែលផ្តល់ដោយមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាព។

**ក.១.៦ MATERIEL OSTEOSYNTHESE** គឺជាលោហៈដែលប្រើប្រាស់សម្រាប់តភ្ជាប់ឆ្អឹងដែលបែកបាក់។

**ក.១.៧ បន្ទប់ម៉ាស៊ីនត្រជាក់** គឺផ្អែកទៅតាមស្ថានភាពជាក់ស្តែង និង ការព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល។

**ក.១.៨ សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះសម្រាប់របបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព** គឺជាការបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ ក្នុងករណីសង្គ្រោះបន្ទាន់ដោយរថយន្តសាមុយ(SAMU) ឬរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាល ឬ មធ្យោបាយផ្សេងៗទៀត ។ ការទូទាត់ថ្លៃសេវាបញ្ជូនត្រូវកំណត់ដោយប.ស.ស ផ្អែកទៅលើប្រភេទមធ្យោបាយបញ្ជូន និងទៅតាមតារាងតម្លៃសេវារបស់មូលដ្ឋានសុខាភិបាលសាធារណៈ ឬបន្ថែម៣០% (សាមសិបភាគរយ)ចំពោះប្រភេទមធ្យោបាយបញ្ជូនដោយរថយន្ត សាមុយ (SAMU) ឬ រថយន្តគិលានសង្គ្រោះ របស់មូលដ្ឋានសុខាភិបាលឯកជន ឬតាមមធ្យោបាយជាក់ស្តែង។

**ក.១.៩ ការបញ្ជូនសព** គឺជាការបញ្ជូនសពឬអ្នកជំងឺធ្ងន់ធ្ងរព្យាបាលមិនជាតាមគ្រប់ប្រភេទមធ្យោបាយបញ្ជូនពីកន្លែងគ្រោះថ្នាក់ ឬពី មូលដ្ឋានសុខា-ភិបាលទៅកាន់លំនៅស្ថានឬឈាបនដ្ឋានសម្រាប់ផ្នែកថែទាំសុខភាព។ ការទូទាត់ថ្លៃសេវាបញ្ជូនសពនេះផ្អែកតាមតម្លៃសេវាមូលដ្ឋានសុខាភិបាលសាធារណៈដែលបានផ្តល់សេវានោះឬផ្អែកទៅតាមតម្លៃកំណត់ដោយ

ប.ស.ស ដោយឈរលើស្ថានភាពទីតាំងភូមិសាស្ត្រ ចម្ងាយ និងប្រភេទមធ្យោបាយបញ្ជូន ។

**ក.១.១០ សេវាស្តារនីតិសម្បទា** គឺជាសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រសម្រាប់ផ្នែកថែទាំសុខភាព ក្នុងគោលបំណងជួយដល់ជនរងគ្រោះ រក្សាស្តារ ឬធ្វើឲ្យប្រសើរឡើងវិញនូវសមត្ថភាពជំនាញ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ និងជំនាញប្រាស្រ័យទាក់ទង ដែលបានបាត់បង់ ឬ ខូចខាតដោយសារជំងឺ រងរបួស ឬពិការភាព។ ការផ្តល់សេវាស្តារនីតិសម្បទា ឬសម្ភារៈបរិក្ខារ និងឧបករណ៍សិប្បនិម្មិត ឬ ត្រូវផ្តល់ទាំងអស់ហើយត្រូវកំណត់ជ្រើសរើស និង វាយតម្លៃដោយ ប.ស.ស ផ្អែកទៅលើស្ថានភាព និងតារាងតម្លៃសេវារបស់អង្គភាព ឬ ស្ថាប័នរដ្ឋ ឬ ឯកជនដែលផ្តល់សេវានោះ។

**ក.២ ករណីពិសេសផ្សេងទៀតដែលគ្មាននៅក្នុងឧបសម្ព័ន្ធទី១**

**ក.២.១ ការចោះ ឬដាប់ឆ្អឹងលលាដ៍ក្បាល (Trepanation)** គឺជាអន្តរាគមន៍វះកាត់ដោយចោះ ឬ ដាប់ឆ្អឹងលលាដ៍ក្បាល ដើម្បីពិនិត្យស្រទាប់ក្រៅ នៃស្រោមខួរក្បាល និងព្យាបាល បញ្ហាសុខភាពទាក់ទង និងជំងឺក្នុងស្រទាប់ក្រៅនៃស្រោមខួរ និងក្នុងខួរក្បាល ដែលផ្តល់ដោយមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាព។

**ក.២.២ ការវះកាត់បេះដូងនិងសរសៃឈាម** គឺជាការវះកាត់បេះដូងនិងសរសៃឈាមធំៗដោយគ្រូពេទ្យឯកទេសវះកាត់បេះដូង ក្នុងករណីសង្គ្រោះបន្ទាន់សម្រាប់ផ្នែកថែទាំសុខភាព។ ចំពោះការវះកាត់បេះដូង និងសរសៃឈាមតាមការគ្រោងទុកមិនត្រូវបានរាប់បញ្ចូលឡើយ។

**ក.២.៣ ការព្យាបាលសង្គ្រោះបន្ទាន់ជំងឺបេះដូង** គឺជាអន្តរាគមន៍ព្យាបាលនិងថែទាំវេជ្ជសាស្ត្រឯកទេសបេះដូងក្នុងគោលបំណងសង្គ្រោះអាយុជីវិតរបស់អ្នកជំងឺ ឬជនរងគ្រោះ សម្រាប់របបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព។

អន្តរាគមន៍នេះសម្រាប់តែមជ្ឈមណ្ឌលព្យាបាលជំងឺបេះដូងភ្នំពេញ ឬ មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងពិសេស ជាមួយបេឡាជាតិរបបសន្តិ-សុខសង្គមប៉ុណ្ណោះ ។

ខ. ប.ស.ស នឹងធ្វើការទូទាត់តាមប្រភេទសេវាសម្រាប់ករណី ក.១ និង ក.២ ដូចខាងក្រោម៖

ខ.១ សម្រាប់ប្រភេទករណីដូចមានចែងក្នុងចំណុច ក.១ នៃឧបសម្ព័ន្ធនេះ មូលដ្ឋានសុខាភិបាលនឹងទទួលបានការទូទាត់តាមប្រភេទសេវាសម្រាប់ថ្លៃសេវាពិសេសបន្ថែម ឬ សេវាព្យាបាល និងថៃទាំបន្តទៅតាមតម្លៃហិរញ្ញប្បទានផ្លូវការរបស់មូលដ្ឋានសុខាភិបាល ឬ ទៅតាមការព្រមព្រៀង។ ការទូទាត់នេះមិនរាប់បញ្ចូលការទូទាត់តាមករណី ដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី១ ទេ។

ខ.២ សម្រាប់ករណីពិសេសដូចមានចែងក្នុងចំណុចក.២ នៃឧបសម្ព័ន្ធនេះមូលដ្ឋានសុខាភិបាល នឹងទទួលបានការទូទាត់ថ្លៃសេវាតាមប្រភេទសេវាហិរញ្ញប្បទានផ្លូវការរបស់មូលដ្ឋានសុខាភិបាល ឬទៅតាមការព្រមព្រៀង។